# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

# គោលនយោបាយ និងបទដ្ឋានអប្បបរមា

# ស្តីពី

# កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស

ឆ្នាំ ២០០៩

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមថ្លែងអំណរគុណចំពោះគម្រោងប្រឆាំងអំពើជួញដូរមនុស្ស ( CTIP ) នៃអង្គការមូលនិធិអាស៊ី ( TAF ) និងទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ ( USAID ) ដែលបានឧបត្ថម្ភផ្នែកបច្ចេកទេស និងការបោះពុម្ពផ្សាយសៀវភៅនេះ ។

USAID
FROM THE AMERICAN PEOPLE

The Asia Foundation

# អារម្ភកថា

ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប៉ិនប្រសប់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាយ៉ាងប្តូរផ្តាច់ឥតរាថយ ក្នុងការបង្កើតបរិស្ថានអនុគ្រោះ និងលក្ខណៈចាំបាច់ជាច្រើន សម្រាប់ឱ្យកម្ពុជាអាចបោះជំហានទៅមុខប្រកបដោយក្តីសង្ឃឹម និងជំនឿទុកចិត្តយ៉ាងមុតមាំ នៅលើមាគ៌ានៃកំណែទម្រង់ និងការអភិវឌ្ឍន៍ ។

រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៤ បានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ដើម្បីកំណើនការងារ សមធម៌ ទិសស្លោកសំខាន់របស់យើងគឺបង្កើនប្រសិទ្ធភាព នៃសេវាសាធារណៈ ។ តាមរយៈយុទ្ធសាស្ត្រនេះ យើងបាន និងកំពុងពង្រឹងសន្តិភាព និងជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច គ្រប់ផ្នែកទទួលបានជោគជ័យជាបន្តបន្ទាប់ និងកំពុងកាត់បន្ថយភាពក្រីក្រជាបណ្តើរៗ ។ គោលនយោបាយរដ្ឋាភិបាលនៅក្នុងប្រទេស ក៏ផ្តោតការយកចិត្តទុកដាក់លើសិទ្ធិមនុស្ស យេនឌ័រ ឆ្លុះបញ្ចាំងនូវការប្តេជ្ញាចិត្តក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ។

រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់ឧបត្ថម្ភរាល់សេចក្តីត្រូវការចាំបាច់ របស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស តាមរយៈការផ្តល់សេវាសមស្រប និងទប់ស្កាត់រាល់អំពើជួញដូរមនុស្សក្នុងប្រទេស និងឆ្លងកាត់ព្រំដែន ជាពិសេសការជួយជនរងគ្រោះ ស្តារនីតិសម្បទា សមាហរណកម្ម និងកិច្ចការពារសិទ្ធិជនរងគ្រោះ។ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ត្រូវបានប្រកាស ឱ្យប្រើកាលពីថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ។ រាជរដ្ឋាភិបាលកម្ពុជាបានចាត់វិធានការសំខាន់ៗ ដែលស្របតាមការតម្រូវជាលក្ខណៈអន្តរជាតិ ដើម្បីបញ្ឈប់អំពើជួញដូរមនុស្ស តាមរយៈសេចក្តីប្រកាស ច្បាប់ អនុស្សារណៈផ្សេងៗ ដូចជា ÷

- សេចក្តីសម្រេចលេខ ៣៥ ស.ស.រ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិ ដើម្បីអនុវត្តកិច្ចព្រមព្រៀងអនុស្សារណៈ ស្តីពីការយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងបណ្តាប្រទេសដែលពាក់ព័ន្ធ ស្តីពីការលុបបំបាត់អំពើជួញដូរមនុស្ស និងជួយជនរងគ្រោះដោយអំពើជួញដូរ ។
- សេចក្តីសម្រេចលេខ ៤១ ស.ស.រ ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតឡើងនូវក្រុមការងារដឹកនាំប្រឆាំងអំពើជួញដូរមនុស្ស អំពើរត់ពន្ធមនុស្ស អំពើធ្វើអាជីវកម្មលើកម្លាំងពលកម្ម និងផ្លូវភេទលើស្ត្រី និងកុមារ ។
- សេចក្តីសម្រេចលេខ ២៨១៥ ស.ស.រ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការតែងតាំងលេខាធិការដ្ឋានក្រុមការងារជួរមុខប្រឆាំងអំពើជួញដូរមនុស្ស អំពើរត់ពន្ធមនុស្ស អំពើធ្វើអាជីវកម្មលើកម្លាំងពលកម្ម និងផ្លូវភេទលើស្ត្រី និងកុមារ ។

នៅលើទិដ្ឋភាពផ្នែកច្បាប់ ការទិញលក់មនុស្សសម្រាប់បម្រើផ្លូវភេទ ឬសម្រាប់គោលបំណងផ្សេងពីនេះណាមួយ គឺជាបទឧក្រិដ្ឋទាំងនៅអន្តរជាតិ និងទាំងនៅក្នុងប្រទេសកម្ពុជា ។ វាគឺជាឧក្រិដ្ឋកម្មដ៏អាក្រក់បំផុត ជាឧក្រិដ្ឋកម្មដែលបន្ទាបបន្ថោកតម្លៃមនុស្ស និងជាន់ឈ្លីសិទ្ធិមនុស្សដើម្បីផលចំណេញ ។ វាជាឧក្រិដ្ឋកម្មមួយ ដែលកងកម្លាំងនគរបាល មន្ត្រីត្រួតពិនិត្យច្រកព្រំដែន និងអាជ្ញាធរមានសមត្ថកិច្ចទាំងអស់ មិនព្រងើយកន្តើយឡើយ ។ ការឆ្លើយតបផ្នែកច្បាប់ចំពោះបញ្ហាជួញដូរមនុស្ស ត្រូវតែឱ្យមានយុត្តិធម៌មិនរើសអើង ដើម្បីធានាថា ឧក្រិដ្ឋជនជួញដូរមនុស្សដឹងថា អំពើឧក្រិដ្ឋ

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ គម្រោងប្រឆាំងអំពើជួញដូរមនុស្សរបស់ អង្គការមូលនិធិអាស៊ី ( CTIP- The Asia Foundation ) និងទីភ្នាក់ងារសហរដ្ឋអាមេរិក សម្រាប់កិច្ចអភិវឌ្ឍន៍អន្តរជាតិ ( USAID ) ដែលបានសហការជាមួយមន្ត្រីជំនាញបច្ចេកទេស របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រៀបចំ និងចងក្រងគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្សនេះឡើង ។

ក្រសួងសូមស្វាគមន៍ ចំពោះការផ្តល់មតិស្ថាបនា ពីគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ ដើម្បីកែលម្អឯកសារគោលនយោបាយ និងបទដ្ឋានអប្បបរមានេះ ឱ្យបានកាន់តែល្អប្រសើរឡើង និងស្របតាមស្ថានការណ៍ជាក់ស្តែងរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅកម្ពុជា ។

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ០១ ឆ្នាំ ២០០៩

រដ្ឋមន្ត្រី

អ៊ិត សំហេង

**IV. គោលការណ៍ស្ដីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស**.................... ១៧
- លិខិតបទដ្ឋានដែលដាក់ឱ្យប្រើ .................................................................................. ១៧
- សិទ្ធិទាំង១១ របស់ជនរងគ្រោះ.................................................................................. ១៨

**V. គោលនយោបាយទូទៅស្ដីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស**.... ១៩
១. ចក្ខុវិស័យ ........................................................................................................ ១៩
២. បេសកកម្ម........................................................................................................ ១៩
៣. ទិសដៅទូទៅ ..................................................................................................... ២០
៤. ឧបសគ្គ........................................................................................................... ២០
៥. កាលានុវត្តភាព................................................................................................... ២១
៦. យុទ្ធសាស្ត្រ ....................................................................................................... ២១

**VI. ទិសដៅកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស**.................................. ២២
ក. ការទទួលជនរងគ្រោះ ដែលបានធ្វើមាតុភូមិនិវត្តន៍ពីក្រៅប្រទេស .................................... ២២
ខ. ការបញ្ជូនជនរងគ្រោះត្រឡប់ទៅប្រទេសកំណើត........................................................ ២២
គ. ការទទួលជនរងគ្រោះពីសមត្ថកិច្ចរបស់មន្ទីរស.អ.យ រាជធានី ខេត្ត................................ ២២
ឃ. ការធ្វើសមាហរណកម្មជនរងគ្រោះត្រលប់ទៅគ្រួសារ សហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល.. ..................................................................... ២២

**VII. ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ចនៃរាជរដ្ឋាភិបាល និងការប្ដេជ្ញាចិត្តរបស់មន្ត្រី និងភ្នាក់ងារផ្ដល់កិច្ចការពារសិទ្ធិជនរងគ្រោះ** ........................................ ២២
១- ការទទួលខុសត្រូវរបស់ ក្រសួង ស្ថាប័នមានសមត្ថកិច្ចនៃរាជរដ្ឋាភិបាល............................ ២២
២- ការប្ដេជ្ញាចិត្តរបស់មន្ត្រីរាជរដ្ឋាភិបាល បុគ្គលិក អង្គការមិនមែនរដ្ឋាភិបាល ក្នុងការផ្ដល់កិច្ចការពារសិទ្ធិជនរងគ្រោះ ................................................................................... ២៣
៣- សហប្រតិបត្តិការរបស់រាជរដ្ឋាភិបាលកម្ពុជាជាមួយប្រទេសជិតខាង និងអង្គការមិនមែនរដ្ឋាភិបាលលើកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ........................................ ២៤
ក. សហប្រតិបត្តិការជាមួយប្រទេសជិតខាង.................................................... ២៤
ខ. សហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល (NGOs)................................ ២៤

៨- សមាហរណកម្ម ........ ៣៧
៩- ការតាមដាន ........ ៣៨
១០- ការបិទករណី ........ ៣៨
**ប្រការ ៨.–** ការថែទាំខ្លួនសម្រាប់អ្នកផ្តល់សេវា ........ ៣៩
១- ការថែទាំខ្លួនសម្រាប់អ្នកផ្តល់សេវា ........ ៣៩
២- អ្នកគ្រប់គ្រងអ្នកផ្តល់សេវា ........ ៤០
**ជំពូកទី ៣**
**ការគ្រប់គ្រងករណី**
**ប្រការ ៩.–** ដំណើរការ នៃការធ្វើសមាហរណកម្ម ........ ៤០
១- ដំណាក់កាលមុនពេលសមាហរណកម្ម ........ ៤០
២- ដំណាក់កាលធ្វើសមាហរណកម្ម ........ ៤០
៣- ការតាមដានប្រភេទ ១ ........ ៤០
៤- ការតាមដានប្រភេទ ២ ........ ៤០
**ប្រការ ១០.–** តួនាទី និងភារកិច្ចរបស់មន្ត្រី បុគ្គលិកទទួលបន្ទុកផ្តល់សេវាកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ........ ៤១
**ប្រការ ១១.–** ការរៀបចំ និងតម្កល់ឯកសារ ........ ៤១
**ប្រការ ១២.–** ប្រព័ន្ធផ្សព្វផ្សាយ ........ ៤២
**ជំពូកទី ៤**
**ការត្រួតពិនិត្យកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស**
**ប្រការ ១៣.–** ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ លើកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ........ ៤៣
**ជំពូកទី ៥**
**អវសានប្បញ្ញត្តិ**
**ប្រការ ១៤.–** ការទុកជានិរាករណ៍ ........ ៤៤
**ប្រការ ១៥.–** ការដាក់ឱ្យអនុវត្ត ........ ៤៤
**ប្រការ ១៦.–** កាតព្វកិច្ចអនុវត្ត ........ ៤៤

**ប្រការ ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣.-**

នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការ នៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធាននាយកដ្ឋានសុខុមាលភាពសង្គម និងប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត និងអង្គភាពពាក់ព័ន្ធនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានភារកិច្ចរៀងៗខ្លួន អនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលារាជធានី ខេត្ត
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- គ្រប់អង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ
- ដូចប្រការ ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

រដ្ឋមន្ត្រី

**អ៊ិត សំហេង**

ទុកបញ្ហាប្រឈមជាច្រើន ។ ភាពក្រីក្រកើតមានឡើងភាគច្រើននៅតាមទីជនបទ ហើយភាគច្រើននៃអ្នកទាំងនោះត្រូវបានប្រឈមមុខនឹងគ្រោះធម្មជាតិ និងរងគ្រោះដោយប្រការផ្សេងៗទៀត។ ជារៀងរាល់ឆ្នាំប្រជាជនមួយចំនួនបានធ្វើចំណាកស្រុកមកកាន់ទីប្រជុំជន ដើម្បីស្វែងរកការងារធ្វើនៅ តាមបណ្តាក្រុមហ៊ុន រោងចក្រ សហគ្រាស ឬតាមផ្ទះឯកជនក្នុងប្រទេស និងមួយចំនួនទៀតក៏បានទៅស្វែងរកការងារធ្វើនៅប្រទេសជិតខាង ដើម្បីជួយរកប្រាក់ចំណូលសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ តាមរយៈការសន្យារកការងារឱ្យធ្វើរបស់ក្រុមឈ្មួញកណ្តាល ( មេខ្យល់ ) ដែលពួកទាំងនេះច្រើនតែជាក្រុមជនទុច្ចរិតរកស៊ីបោកប្រាស់ ។

អំពើជួញដូរមនុស្សមានការរីករាលដាលនៅក្នុងប្រទេសកម្ពុជាចាប់តាំងពី ឆ្នាំ ១៩៩០ ។ ការសិក្សាស្រាវជ្រាវនាពេលថ្មីៗនេះ ដោយអង្គការ UNIAP បានរកឃើញថា អ្នកធ្វើចំណាកស្រុកខុសច្បាប់ដែលត្រូវគេចាប់បញ្ជូនមកពីប្រទេសថៃ ចំនួន ២៩ % ជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ការសិក្សាស្រាវជ្រាវនាពេលថ្មីៗនេះមួយទៀតរបស់អង្គការ UNIAP ក៏បានរកឃើញដែរថា អ្នកប្រកបរបររកស៊ីផ្លូវភេទចំនួន ៩% ត្រូវគេឆបោក។ នៅក្នុងឆ្នាំ ២០០៨ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានទទួល និងស្តារនីតិសម្បទា ជនរងគ្រោះជាស្ត្រី និងកុមារ ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសថៃ ចំនួន ១០៥ នាក់ ក្នុងនោះមាន ០៧ នាក់ ត្រូវបានគេជួញដូរផ្លូវភេទ និងជនរងគ្រោះជនជាតិខ្មែរ ចំនួន ៧៤៥ នាក់ រងគ្រោះដោយអំពើជួញដូរកម្លាំង ពលកម្ម ដែលបានធ្វើមាតុភូមិនិវត្តន៍ពីប្រទេសវៀតណាម និងបានធ្វើការបញ្ជូនត្រឡប់ក្មេងស្រីជនជាតិវៀតណាម ចំនួន ០៤ នាក់ រងគ្រោះដោយអំពើជួញដូរផ្លូវភេទត្រឡប់ទៅប្រទេសវៀតណាមវិញ និងបានទទួល និងស្តារនីតិសម្បទា ជនរងគ្រោះជនជាតិខ្មែរ ដែលបានធ្វើមាតុភូមិនិវត្តន៍ពីប្រទេសម៉ាឡេស៊ី ចំនួន ១៨ នាក់ ដែលត្រូវបានគេជួញដូរ ឱ្យទៅធ្វើជាកម្មករនេសាទ ។ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានីភ្នំពេញ បានសហការជាមួយ មន្ត្រីនគរបាលប្រឆាំងការជួញដូរ និងការពារអនីតិជន បានជួយសង្គ្រោះក្មេងស្រីរងគ្រោះដោយ អំពើជួញដូរមនុស្ស បានចំនួន ៥០៥ នាក់ និងបានបញ្ជូនបន្តទៅអង្គការដៃគូ ដើម្បីទទួលនូវសេវាជាជម្រក សេវាសុខភាព សេវាអប់រំ សេវាផ្គត់ផ្គង់ជីវភាព សេវាបណ្តុះបណ្តាលវិជ្ជាជីវៈ និងធ្វើសមាហរណកម្មទៅរួមរស់នៅក្នុងគ្រួសារ និងសហគមន៍ របស់គេវិញ ។ពួកគេភាគច្រើនត្រូវគេអូសទាញធ្វើការងារបម្រើផ្លូវភេទ ដែលផ្ទុយនឹងឆន្ទៈរបស់គេក្នុងករណីអនីតិជន។ អំពើជួញដូរឆ្លងដែន ក៏ជាបញ្ហាមួយដែលកំពុងតែទទួលបានការចាប់អារម្មណ៍ដែរ ។ ស្ត្រីវ័យក្មេងជាជនបរទេសត្រូវ គេជួញដូរឱ្យធ្វើការបម្រើផ្លូវភេទ និងពលកម្មបង្ខំនៅក្នុងប្រទេសកម្ពុជា ហើយមាន បុរស ស្ត្រី និងកុមារកម្ពុជាក៏ត្រូវ គេជួញដូរទៅប្រទេសជិតខាងផងដែរ សម្រាប់ធ្វើការបម្រើផ្លូវភេទ ពលកម្មបង្ខំ និងការងារនេសាទ។

អំពើជួញដូរមនុស្សកើតឡើងក្នុងបីដំណាក់កាល : ការជ្រើសរើស ការដឹកជញ្ជូន និង ការកេងប្រវ័ញ្ចន៍ លើបុគ្គល [១]។ អំពើជួញដូរមនុស្សមិនកើតឡើងក្នុងភាពដាច់ដោយឡែកនោះទេ។ អំពើជួញដូរមនុស្សអាចកើតឡើងស្របពេលជាមួយនឹងការកេងប្រវ័ញ្ចន៍ផ្លូវភេទ អំពើហិង្សា ឬ ការរត់ពន្ធមនុស្ស ។ ចំណាកស្រុកស្របច្បាប់ ឬ

---

១ កម្មវិធីស្តីពីច្បាប់បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ចន៍ផ្លូវភេទ រៀបចំដោយគម្រោងប្រឆាំងអំពើជួញដូរមនុស្សនៅតំបន់អាស៊ី ឆ្នាំ ២០០៩ ។

### ខ. នៅមណ្ឌលសំចតរយៈពេលខ្លី

ជនរងគ្រោះអាចចូលមណ្ឌលសំចតរយៈពេលខ្លី បន្ទាប់ពីទទួលបានការកំណត់អត្តសញ្ញាណរួចរាល់ ជនរងគ្រោះអាចទទួលរងការប៉ះទង្គិចផ្លូវចិត្តនៅដំណាក់កាលនេះ ហើយអាចបង្ហាញនូវអាកប្បកិរិយាខុសប្រក្រតី ។ មណ្ឌលសំចតរយៈពេលខ្លី ត្រូវផ្ដល់ការគាំទ្របែបប៉ាន់ប្រមាណ និងថែទាំល្អិតល្អន់ កំណត់ឱ្យបាននូវតម្រូវការបន្ទាន់របស់ជនរងគ្រោះ និងផ្ដល់នូវការប្រាស្រ័យទាក់ទងទៅរកសេវាខាងក្រៅ ។

ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅមណ្ឌលសំចតរយៈពេលខ្លី ត្រូវមានការចូលរួមពី មន្ត្រីបុគ្គលិកសង្គមកិច្ច អ្នកពិគ្រោះយោបល់ និងអ្នកថែទាំ ។ ជនរងគ្រោះអាចទទួលបាននូវសេវា សុខភាពពីគ្រូពេទ្យ ដូចជាវេជ្ជបណ្ឌិត ឬ គិលានុបដ្ឋាយិកា អាស្រ័យលើតម្រូវការរបស់ជនរងគ្រោះ ។ ចៅក្រមស៊ើបអង្កេត និងអ្នកផ្ដល់សេវាជំនួយផ្នែកច្បាប់ អាចប្រាស្រ័យទាក់ទងជាមួយជនរងគ្រោះបានក្នុងបរិបទនេះ ។ គេចាំបាច់ត្រូវធានា ថាការសាកសួរជាសំណួរមានភាពជិតស្និទ្ធ ហើយមិនបង្កឱ្យមានការប៉ះទង្គិចផ្លូវចិត្តជនរងគ្រោះ។

### គ. មណ្ឌលរយៈពេលយូរ

ជនរងគ្រោះអាចចូលមណ្ឌលរយៈពេលយូរប្រសិនបើពុំអាចរកគ្រួសារឃើញ ឬ ប្រសិនបើគេពុំអាចវិលត្រឡប់ទៅគ្រួសារវិញសម្រាប់ហេតុផលសុវត្ថិភាព ។ ក្នុងមណ្ឌលរយៈពេលយូរជនរងគ្រោះត្រូវទទួលបានសេវា សុខភាព កិច្ចការពារសិទ្ធិផ្នែកច្បាប់ ការអប់រំតាមសាលា ការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈ ការពិគ្រោះយោបល់ និងជំនាញបំណិនជីវិតដែលសមស្រប ។

ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវមានការចូលរួមពីមន្ត្រី បុគ្គលិកសង្គមកិច្ច អ្នកពិគ្រោះយោបល់ និងអ្នកថែទាំ ។ អ្នកដែលពាក់ព័ន្ធទាំងអស់នេះត្រូវដឹងពីផែនការករណីរបស់ជនរងគ្រោះ ក៏ដូចជាផែនការស្ដារនីតិសម្បទា ។ ជនរងគ្រោះអាចទទួលបាននូវសេវាសុខភាពពីគ្រូពេទ្យដូចជាវេជ្ជបណ្ឌិត ឬ គិលានុបដ្ឋាយិកា អាស្រ័យលើតម្រូវការរបស់ជនរងគ្រោះ ។ ចៅក្រមស៊ើបអង្កេត និងអ្នកផ្ដល់សេវាជំនួយផ្នែកច្បាប់ អាចប្រាស្រ័យទាក់ទងជាមួយជនរងគ្រោះបានក្នុងបរិបទនេះ។ គេចាំបាច់ត្រូវធានាថារាល់ការសាកសួរត្រូវមានភាពជាស្និទ្ធស្នាល ហើយមិនបង្កឱ្យមានការប៉ះទង្គិចផ្លូវចិត្តជនរងគ្រោះ។

### ឃ. នៅសហគមន៍

ជនរងគ្រោះអាចមានជម្រើសវិលត្រឡប់ទៅកាន់សហគមន៍វិញ ដោយមានសិទ្ធិមិនទទួលយកការថែទាំនៅក្នុងមណ្ឌល ឬជនរងគ្រោះអាចជ្រើសរើសយកសេវាស្ដារនីតិសម្បទានៅក្នុងមណ្ឌល ហើយត្រៀមខ្លួនត្រឡប់ទៅកាន់សហគមន៍វិញ ។

ការថែទាំជនរងគ្រោះនៅតាមសហគមន៍គឺជាភារកិច្ចសំខាន់ និងមានការលំបាក ។ អ្នកផ្ដល់ការថែទាំដែលក្ដាប់បានតិចតួចពីបរិយាកាសនៅសហគមន៍ ចាំបាច់ត្រូវយល់ដឹងពីគន្លឹះអារម្មណ៍ ដែលអាចធ្វើឱ្យជនរងគ្រោះទទួលរងការប៉ះទង្គិចផ្លូវចិត្តសាជាថ្មី។ អ្នកផ្ដល់សេវាចាំបាច់ត្រូវជម្រាបជូនជនរងគ្រោះពីកន្លែងជិតបំផុត ដែលជនរងគ្រោះអាចទទួលបានសេវាវេជ្ជសាស្ត្រ ចិត្តសាស្ត្រ និងហិរញ្ញវត្ថុ។

អន្តរាគមន៍វិបត្តិអាចកើតឡើងភ្លាមៗ ជាមួយដំណាក់កាលកំណត់អត្តសញ្ញាណជនរងគ្រោះ ។ នគរបាលអាចរៀបចំធ្វើការបង្រ្កាប សង្រ្គោះ ដើម្បីយកជនរងគ្រោះចេញពីស្ថានការណ៍ជួញដូរ តាមការពិគ្រោះយោបល់ជាមួយមន្ត្រីសង្គមកិច្ចដើម្បីធានាឱ្យជនរងគ្រោះបានចេញទៅកាន់កន្លែងដែលមានសុវត្ថិភាព និងផ្តល់នូវជំនួយសង្រ្គោះបន្ទាន់ដែលចាំបាច់នានាដូចជា មណ្ឌល អាហារ ការថែទាំវេជ្ជសាស្រ្ត និងផ្លូវចិត្ត។

អន្តរាគមន៍វិបត្តិក៏អាចកើតមានឡើងនៅក្នុងដំណើរការស្តារនីតិសម្បទា។ ឧប្បត្តិហេតុមួយដែលបង្ហាញថាមនុស្សម្នាក់គ្មានសុវត្ថិភាព ឬ មានគ្រោះថ្នាក់ផ្លូវកាយ ផ្លូវចិត្ត ទាមទារឱ្យមានការធ្វើអន្តរាគមន៍។ ឧទាហរណ៍ អស្ថេរភាពផ្លូវចិត្ត ដូចជានិន្នាការធ្វើអត្តឃាត គឺចាំបាច់មានអន្តរាគមន៍វិបត្តិ។ ជនរងគ្រោះត្រូវធ្វើសមាហរណកម្មទៅកាន់សហគមន៍វិញ ហើយជនរងគ្រោះនោះត្រូវផ្តល់ព័ត៌មានដល់អ្នកផ្តល់សេវាអំពីអ្នកជួញដូរមនុស្ស ដែលបង្ហាញខ្លួននៅក្នុងសហគមន៍ម្តងទៀត ក្នុងករណីនេះចាំបាច់ត្រូវមានកិច្ចអន្តរាគមន៍ជាបន្ទាន់។

**ការបញ្ជូន** ជាដំណើរការរៀបចំបញ្ជូន ឬ ផ្ទេរជនរងគ្រោះទៅរកសេវាណាមួយសមស្រប។ អ្នកបញ្ជូនត្រូវផ្តល់ព័ត៌មានច្បាស់លាស់អំពីលទ្ធផលរំពឹងទុកជាមួយអ្នកទទួល ដើម្បីឱ្យអ្នកទទួលត្រៀមខ្លួនឆ្លើយតបទៅនឹងតម្រូវការរបស់ជនរងគ្រោះ ។ ព័ត៌មាននៃការបញ្ជូន ត្រូវផ្តល់ដល់ជនរងគ្រោះឱ្យបានដឹងជាមុន និងមានការយល់ព្រមពីជនរងគ្រោះ ។

**ការទទួល** ជាការទទួលយក និងផ្តល់សេវាដល់ជនរងគ្រោះ។ ការទទួលយកអាចកើតមានឡើងនៅទីកន្លែងជាច្រើនសម្រាប់ជនរងគ្រោះរួមមាន ប៉ុស្តិ៍នគរបាល មណ្ឌល មន្ទីរពេទ្យ និងកន្លែងបណ្តុះបណ្តាលជំនាញផ្សេងៗ។

ការទទួលគឺជាចំណុចចាប់ផ្តើមដំបូង ដែលជនរងគ្រោះទទួលបានពីអ្នកផ្តល់សេវា។ ការចាប់ផ្តើមនេះត្រូវធ្វើឱ្យមានឥទ្ធិពលដល់ជនរងគ្រោះនូវអារម្មណ៍សុវត្ថិភាព ហើយក៏ជាចំណុចផ្តើមរបស់ជនរងគ្រោះមាន ឬ គ្មានទំនុកចិត្តចំពោះអ្នកផ្តល់សេវា។ ហើយប្រការនេះ ក៏អាចជះឥទ្ធិពលដល់បំណងសហការ និងការផ្តល់ព័ត៌មានដល់អ្នកផ្តល់សេវារួមទាំងនគរបាលផង។

**ការរៀបចំផែនការករណី** គឺជាដំណើរការកំណត់ទិសដៅសម្រាប់ដំណោះស្រាយដោយជោគជ័យ លើបញ្ហារបស់ជនរងគ្រោះ ដែលក្នុងនោះគោលដៅ និងទិសដៅ ព្រមទាំងវិធានការ និងធនធានត្រូវបានកំណត់ និងទទួលបាន។ ការរៀបចំផែនការករណី គឺជាសកម្មភាពដែលកើតឡើងជាបន្តបន្ទាប់ក្នុងដំណើរការជួយជនរងគ្រោះ ហើយជនរងគ្រោះត្រូវបានជំរុញឱ្យចូលរួមយ៉ាងសកម្មក្នុងផែនការករណីរបស់ខ្លួន។

ការរៀបចំផែនការករណីអាចធ្វើឡើងបានល្អបំផុតតាមរយៈក្រុមការងារចម្រុះ ។ ក្រុមការងារនេះរួមមាន ៖ ជនរងគ្រោះ អ្នកគ្រប់គ្រងករណី (មន្ត្រី បុគ្គលិកសង្គមកិច្ច) ហើយនិងអ្នកដែលមានតួនាទីពាក់ព័ន្ធដល់ដំណើរការជួយជនរងគ្រោះ។

ការរៀបចំផែនការករណី និង/ឬ ការវិវត្តផែនការករណីចាំបាច់ត្រូវមានការកត់ត្រាពីគោលបំណង ទិសដៅបញ្ហាប្រឈម និងនីតិវិធីនៃការដោះស្រាយបញ្ចូលក្នុងសំណុំឯកសាររបស់ជនរងគ្រោះ។

**ការប៉ាន់ប្រមាណ** ជាដំណើរការពិនិត្យ និងវាយតម្លៃលើករណីជាក់លាក់ដូចជា ការប៉ាន់ប្រមាណសុខភាព ឬ ការប៉ាន់ប្រមាណករណីបឋម និងការប៉ាន់ប្រមាណគ្រួសារ និងសហគមន៍ ដើម្បីឈានទៅដល់ការដោះស្រាយបញ្ហាការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មជនរងគ្រោះ។

- ស្ថានភាពសេដ្ឋកិច្ចរបស់គ្រួសារមានលំនឹងអាចរស់បានដូចអ្នកដទៃ។

- ជនដែលត្រូវធ្វើសមាហរណកម្ម បានចូលរួមក្នុងសកម្មភាពធម្មតា និងជាប្រចាំដូចជា ទៅរៀន រកប្រាក់ចំណូល (នៅក្នុង ឬ នៅក្រៅផ្ទះ) ទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈជាដើម។

- មានភស្តុតាងគ្រប់គ្រាន់បង្ហាញថា ជនដែលត្រូវធ្វើសមាហរណកម្មមានស្ថេរភាព ទាំងផ្នែកសេដ្ឋកិច្ច និងផ្នែកចិត្តសាស្ត្រសង្គម។

ក្នុងស្ថានភាពដែលជនរងគ្រោះទទួលការប៉ះទង្គិចផ្លូវចិត្តសាជាថ្មី ចាំបាច់ត្រូវកំណត់អត្តសញ្ញាណ និងបើកករណីឡើងវិញ។

## IV. គោលការណ៍ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស

រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់ឧបត្ថម្ភរាល់សេចក្តីត្រូវការចាំបាច់របស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស តាមរយៈការផ្តល់សេវាសមស្រប និងទប់ស្កាត់រាល់អំពើជួញដូរមនុស្សក្នុងប្រទេស និងឆ្លងកាត់ព្រំដែន ជាពិសេសការពារសិទ្ធិជនរងគ្រោះ។ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ត្រូវបានប្រកាសឱ្យប្រើកាលពីថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ។ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតក្រុមការងារដឹកនាំប្រឆាំងអំពើជួញដូរមនុស្ស អំពើរត់ពន្ធមនុស្ស អំពើធ្វើអាជីវកម្មលើកម្លាំងពលកម្ម និងផ្លូវភេទ លើស្ត្រី និងកុមារ កាលពីថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៧ ។ រាជរដ្ឋាភិបាលកម្ពុជាបានចាត់វិធានការ សំខាន់ៗដែលស្របតាមការតម្រូវជាលក្ខណៈអន្តរជាតិ ដើម្បីបញ្ឈប់អំពើជួញដូរមនុស្សតាមរយៈសេចក្តីប្រកាស ច្បាប់ អនុស្សរណៈផ្សេងៗដូចខាងក្រោម :

- ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលប្រកាសឱ្យប្រើនៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨។

- សេចក្តីណែនាំលេខ ០០៩ ស.អ.យ ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៧ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការងារសមាហរណកម្ម និងតាមដាន ក្រុមជនរងគ្រោះដែលបានស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល។

- សេចក្តីសម្រេចលេខ ៣៥ ស.ស.រ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិ ដើម្បីអនុវត្តកិច្ចព្រមព្រៀងអនុស្សរណៈស្តីពីការយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងបណ្តាប្រទេសដែលពាក់ព័ន្ធ ស្តីពីការលុបបំបាត់អំពើជួញដូរមនុស្ស និងជួយជនរងគ្រោះដោយអំពើជួញដូរ។

- សេចក្តីសម្រេចលេខ ៤១ ស.ស.រ ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០០៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតឡើងនូវក្រុមការងារដឹកនាំប្រឆាំងអំពើជួញដូរមនុស្ស អំពើរត់ពន្ធមនុស្ស អំពើធ្វើអាជីវកម្មកម្លាំងពលកម្ម និងផ្លូវភេទលើស្ត្រី និងកុមារ។

- សេចក្តីសម្រេចលេខ ២៨១៥ ស.ស.រ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការតែងតាំងលេខាធិការដ្ឋានក្រុមការងារជួរមុខប្រឆាំងអំពើជួញដូរមនុស្ស អំពើរត់ពន្ធមនុស្ស អំពើធ្វើអាជីវកម្មកម្លាំងពលកម្ម និងផ្លូវភេទលើស្ត្រី និងកុមារ។

**សិទ្ធិទទួលបានព័ត៌មាន** សំដៅទៅលើសិទ្ធិរបស់ជនរងគ្រោះ ក្នុងការដឹងនូវសេចក្តីលម្អិត និងព័ត៌មានជាក់លាក់ទាំងអស់ដែលទាក់ទងនឹងជនរងគ្រោះ ។ ព័ត៌មាននេះរួមមាន ព័ត៌មានអំពីជម្រើសខាងផ្លូវច្បាប់ រឿងក្តីដែលកំពុងរង់ចាំការវិនិច្ឆ័យ ស្ថានភាពផ្នែកវេជ្ជសាស្ត្ររបស់ជនរងគ្រោះ គ្រួសារ សហគមន៍ និង ការបណ្តុះបណ្តាលជំនាញ រួមទាំងព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងករណីរបស់គេ ។

**សិទ្ធិទទួលបានសេវា** សំដៅទៅលើសិទ្ធិរបស់ជនរងគ្រោះ ក្នុងការទទួលបានការគាំទ្រជំនួយផ្សេងៗពីរដ្ឋាភិបាល និងសង្គមស៊ីវិលដើម្បីគាំទ្រ ការស្តារនីតិសម្បទាជនរងគ្រោះ រហូតដល់ពេលដែលជនរងគ្រោះទទួលបានភាពប្រក្រតីជាធម្មតាវិញ ។

**សិទ្ធិទទួលបានយុត្តិធម៌** សំដៅទៅលើសិទ្ធិជនរងគ្រោះ ត្រូវទទួលបានកិច្ចការពារសិទ្ធិស្មើភាពគ្នានៅចំពោះមុខច្បាប់ ដែលសិទ្ធិនេះក៏មានចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជា និងដោយយោងទៅតាមគោលការណ៍ស្មើភាព និងយុត្តិធម៌សម្រាប់មនុស្សទាំងអស់ ។

**សិទ្ធិទទួលបានប្រក្រតីភាព** សំដៅទៅលើសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានការជួយជ្រោមជ្រែង នៅក្នុងការធ្វើសមាហរណកម្មទៅក្នុងសហគមន៍ និង គ្រួសារ តាមការសម្រេចចិត្តជ្រើសរើសរបស់ខ្លួន និងទទួលបានប្រក្រតីភាពក្នុងជីវិតប្រចាំថ្ងៃដោយគ្មានការរើសអើង។

**សិទ្ធិចូលរួម** សំដៅទៅលើសិទ្ធិជនរងគ្រោះ ទោះជាកុមារ ឬ មនុស្សពេញវ័យ ត្រូវមានសិទ្ធិបញ្ចេញមតិរបស់ខ្លួន និងចូលរួមក្នុងសកម្មភាពនានាដែលពាក់ព័ន្ធខ្លួនក្នុងសង្គម។

**សិទ្ធិសម្រេចចិត្ត** សំដៅទៅលើសិទ្ធិជនរងគ្រោះក្នុងការសម្រេចចិត្តដោយខ្លួនឯងដែលមិនផ្ទុយនឹងច្បាប់ ។

**សិទ្ធិទទួលបានសេរីភាពបម្លាស់ទី** សំដៅលើសិទ្ធិរបស់ជនរងគ្រោះក្នុងការរស់នៅ និង បម្លាស់ទីដោយមានសេរីភាពនៅក្នុងប្រទេសដែលខ្លួនកាន់សញ្ជាតិជាពលរដ្ឋ និង សិទ្ធិទទួលបានការធ្វើមាតុភូមិនិវត្តន៍ ប្រសិនបើស្ថិតនៅក្រៅប្រទេសដែលខ្លួនកាន់សញ្ជាតិជាពលរដ្ឋ ។

## V. គោលនយោបាយទូទៅស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស

### ១. ចក្ខុវិស័យ

ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវទទួលបាននូវសិទ្ធិទាំងឡាយដែលមាននៅត្រង់ចំណុច IV ។ អ្នកផ្តល់សេវា និងមន្ត្រីរដ្ឋាភិបាល ត្រូវបង្ហាញនូវការប្តេជ្ញាចិត្តការពារសិទ្ធិរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីឱ្យជនរងគ្រោះអាចធ្វើសមាហរណកម្មទៅកាន់គ្រួសារ និង/ឬ សហគមន៍វិញ ទាន់ពេលវេលា និងសុវត្ថិភាព។

### ២. បេសកកម្ម

អនុវត្តតាមកម្មវិធីគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងបណ្តាក្រសួងស្ថាប័នផ្សេងៗទៀត បានប្តេជ្ញាអនុវត្តគោលនយោបាយ ការកសាងសមត្ថភាពបុគ្គលិកដែលអនុវត្តជាមួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ព្រមទាំងបង្កើតនូវប្រព័ន្ធត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ដែលធានាការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព និងមានទំនាក់ទំនងសមស្រប រវាងគ្រួសារ និងសហគមន៍របស់ពួកគេ។

- ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ និងជំងឺអេដស៍ ។
- ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ជាប់សារធាតុថ្នាំញៀន ដោយសារសកម្មភាពដែលខ្លួនទទួលរងពីអំពើជួញដូរមនុស្ស ។
- ការអនុវត្តន៍កម្មវិធីទប់ស្កាត់អំពើជួញដូរមនុស្ស នៅមិនទាន់បានទូលំទូលាយ ហើយមានការងារជាច្រើនទៀតដែលសេសសល់ត្រូវធ្វើដើម្បីដោះស្រាយតាមតម្រូវការជនរងគ្រោះ ។
- គ្រួសារ សហគមន៍ និងបុគ្គលិកជំនាញ ខ្វះចំណេះដឹងផ្នែកគាំទ្រ ខ្វះព័ត៌មាន និងសេវាបញ្ជូនដែលកំពុងអនុវត្តបច្ចុប្បន្ន ។
- ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ភាគច្រើនមិនទាន់មានជំនឿទុកចិត្តលើរចនាសម្ព័ន្ធផ្លូវការ និងស្ថាប័នដែលជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។
- រចនាសម្ព័ន្ធរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅមានកម្រិតនៅឡើយ គឺត្រឹមថ្នាក់ ក្រុង ស្រុក ខណ្ឌ ។

## ៥. កាលានុវត្តភាព

ដើម្បីមានសក្តានុពល ក្នុងការរួមវិភាគទានធ្វើឱ្យប្រសើរឡើងដល់ការជួយឧបត្ថម្ភចំពោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចាំបាច់ត្រូវមានកាលានុវត្តភាពមួយចំនួនដូចខាងក្រោម :

- ឆន្ទៈខាងនយោបាយចំពោះកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងជនទាំងឡាយដែលងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ។
- ពង្រីកក្របខណ្ឌច្បាប់ និងពង្រឹងការអនុវត្តន៍ច្បាប់ឱ្យបានគ្រប់គ្រាន់ និងត្រឹមត្រូវ ។
- ការធ្វើវិមជ្ឈការមុខងាររបស់ថ្នាក់ជាតិ នៅថ្នាក់ក្រោមជាតិ បានជួយគាំទ្រដល់ការបង្កើតរចនាសម្ព័ន្ធដែលមានការចូលរួមនៅតាមសហគមន៍ និងគ្រួសារ ។
- គ្រួសារ សហគមន៍ និងមន្ត្រីបុគ្គលិក ដែលផ្តល់សេវាដល់ជនរងគ្រោះ បានទទួលឱកាសក្នុងការបង្កើនសមត្ថភាព ។
- យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល បានឆ្លើយតបទៅនិងសេចក្តីត្រូវការរបស់គ្រួសារក្រីក្រ ដើម្បីទទួលបានការគាំទ្រល្អប្រសើរ ។
- រាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តអនុវត្តដំណោះស្រាយតាមគ្រួសារ ដំណោះស្រាយតាមសហគមន៍ និងដំណោះស្រាយក្នុងពេលរងគ្រោះ និងក្រោយពេលរងគ្រោះ ។

## ៦. យុទ្ធសាស្ត្រ

ដើម្បីការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចាំបាច់ត្រូវមានយុទ្ធសាស្ត្រទូទៅ ដើម្បីដោះស្រាយនូវសេចក្តីត្រូវការរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស តាមរយៈរចនាសម្ព័ន្ធពហុវិស័យ :

- ធ្វើការប៉ាន់ប្រមាណជាទៀងទាត់ អំពីសេចក្តីត្រូវការតាមវិស័យនានា ដែលពាក់ព័ន្ធដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។
- បង្កើតក្របខណ្ឌគោលនយោបាយ ដែលផ្តោតទៅលើកិច្ចការពារសិទ្ធិជនរងគ្រោះ និងធ្វើឱ្យទៅជាផ្លូវការនូវកម្មវិធី និងសេវាដែលលើកស្ទួយសុខុមាលភាពរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

ខ- ផ្សព្វផ្សាយ និង ធានាការអនុវត្តន៍គោលនយោបាយ ច្បាប់ ឯកសារ និង លិខិតបទដ្ឋានផ្សេងៗទៀតឱ្យមានប្រសិទ្ធភាពលើបញ្ហាដែលពាក់ព័ន្ធនឹងកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

គ- បង្កើត និង អនុម័តបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

ឃ- ផ្អែកតាមការអនុវត្តន៍បទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវពិនិត្យ តាមដាន វាយតម្លៃ និងផ្តល់ការអនុញ្ញាត ដល់អ្នកផ្តល់សេវាការពារសិទ្ធិជនរងគ្រោះទាំងឡាយរបស់រដ្ឋ និងរបស់អង្គការមិនមែនរដ្ឋាភិបាលនានា ។

ង- បែងចែកថវិកាសម្រាប់ឧបត្ថម្ភដល់កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ស្របតាមអ្នកទទួលផលពីគោលនយោបាយ ពីបទដ្ឋានអប្បបរមា ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើតួនាទីរបស់មន្ត្រីរាជការ ក្នុងការប្រតិបត្តិ ពិនិត្យ តាមដាន និងវាយតម្លៃ។

ច- កៀរគររកថវិកាដើម្បីជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស បង្កលក្ខណៈងាយស្រួលជួយដល់ទីភ្នាក់ងារ កិច្ចការពារសិទ្ធិជនរងគ្រោះរបស់អង្គការមិនមែនរដ្ឋាភិបាល និងផ្តល់យោបល់ដល់ការអនុវត្តន៍ការងារប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។

ឆ- ដឹកនាំសម្របសម្រួល និងផ្តល់កិច្ចសហប្រតិបត្តិការដល់ដៃគូអភិវឌ្ឍន៍លើបញ្ហាដែលពាក់ព័ន្ធនឹងកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

ជ- អនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ក្នុងតួនាទីជាប្រធានក្រុមកម្រងផ្នែកកិច្ចការការពារ និងសមាហរណកម្មនៃក្រុមការងារដឹកនាំប្រឆាំងអំពើជួញដូរមនុស្ស រត់ពន្ធមនុស្ស និងកេងប្រវ័ញ្ចន៍ផ្លូវភេទលើស្ត្រី និងកុមារ ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**២- ការប្តេជ្ញាចិត្តរបស់ មន្ត្រីរាជរដ្ឋាភិបាល បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ក្នុងការផ្តល់កិច្ចការពារសិទ្ធិជនរងគ្រោះ :**

ក- សហការជាមួយស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលជួយពិនិត្យឡើងវិញ ការរៀបចំ និងផ្សព្វផ្សាយគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានផ្សេងៗទៀត ឱ្យស្របទៅតាមអនុសញ្ញាស្តីពីសិទ្ធិមនុស្ស ដែលមានការពាក់ពន្ធ័ដល់កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

ខ- អនុវត្តគោលនយោបាយ ច្បាប់ ឯកសារ និងលិខិតបទដ្ឋានផ្សេងៗទៀត ដើម្បីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ឱ្យមានប្រសិទ្ធភាព ។

គ- ពិនិត្យ តាមដាន និងវាយតម្លៃសកម្មភាពការងារខ្លួនផ្ទាល់ ផ្តល់របាយការណ៍ ព្រមទាំងជួយសម្រួលដល់ការពិនិត្យ តាមដាន វាយតម្លៃ ដោយមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាឱ្យសមស្របទៅតាមគោលនយោបាយ និងបទដ្ឋានអប្បបរមា ។

ឃ- អង្គការមិនមែនរដ្ឋាភិបាលត្រូវសុំការអនុញ្ញាត និងចុះកិច្ចព្រមព្រៀងជាមួយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

២. សហការជាមួយអង្គការជាតិ អង្គការមិនមែនរដ្ឋាភិបាលនានា ក្នុងការទំនាក់ទំនងជាមួយអាជ្ញាធរដែនដី ក្នុងករណីអនុវត្តផែនការ កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងក្នុងបញ្ហាពាក់ព័ន្ធត្រូវសហការដោះស្រាយ ។

៣. សហការទំនាក់ទំនងជាមួយអង្គការជាតិ អន្តរជាតិ ក្នុងកិច្ចដំណើរការគ្រប់គ្រងករណី ។

៤. ធ្វើការសហការ ដើម្បីទប់ស្កាត់ការធ្វើចំណាកស្រុកគ្មានសុវត្ថិភាព ។

៥. ពង្រឹង និងពង្រីកកិច្ចសហការរវាង អង្គការជាតិ អន្តរជាតិ ផ្សព្វផ្សាយអំពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។ ៸៷

រដ្ឋមន្ត្រី

អ៊ិត សំហេង

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់ និងដាក់ឱ្យអនុវត្តបទដ្ឋានអប្បបរមា សម្រាប់កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលឧបត្ថម្ភដោយស្ថាប័នរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងសប្បុរសជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ២.-**

បទដ្ឋានអប្បបរមាសម្រាប់កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ប្រកាន់យកយុទ្ធសាស្ត្រការពារផលប្រយោជន៍ជនរងគ្រោះជាចម្បង និងឈរលើមូលដ្ឋានសិទ្ធិរបស់ជនរងគ្រោះ ដោយផ្តោតសំខាន់ទៅលើតម្រូវការរបស់ជនរងគ្រោះ ក្នុងដំណើរការជួយឧបត្ថម្ភជាទូទៅ ។ បទដ្ឋាននេះផ្អែកលើដំណាក់កាលនានានៅក្នុងដំណើរការគ្រប់គ្រងករណី ។

បទដ្ឋានអប្បបរមានេះអនុវត្តចំពោះមនុស្សទាំងអស់ ដែលផ្តល់ជំនួយជូនដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្នុងនោះរាប់បញ្ចូលទាំងមន្ត្រីសង្គមកិច្ច មន្ត្រីពង្រឹងការអនុវត្តច្បាប់ សេវាផ្សេងៗ និងអ្នកផ្តល់សេវាជាតិ និងអន្តរជាតិទាំងអស់ដែលធ្វើការនៅក្នុងប្រទេសកម្ពុជា ។

**ប្រការ ៣.-**

បទដ្ឋានអប្បបរមាសម្រាប់កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលដាក់ឱ្យអនុវត្តក្នុងប្រកាស នេះអនុវត្តតាមស្ថានភាពដូចខាងក្រោម :

**១- នៅមណ្ឌលសំចតរយៈពេលខ្លី**

កិច្ចការពារនៅតាមមណ្ឌលសំចតរយៈពេលខ្លី គឺជាការគាំទ្រ និងការពារថែទាំល្អិតល្អន់ កំណត់ឱ្យបាននូវតម្រូវការបន្ទាន់របស់ជនរងគ្រោះ និងផ្តល់ការប្រាស្រ័យទាក់ទងទៅរកសេវាខាងក្រៅ ។

**២- នៅមណ្ឌលរយៈពេលយូរ**

កិច្ចការពារនៅមណ្ឌលរយៈពេលយូរ គឺជាកន្លែងផ្តល់សេវាសុខភាព កិច្ចការពារផ្លូវច្បាប់ ការអប់រំចំណេះទូទៅ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ការពិគ្រោះយោបល់ និងជំនាញបំណិនជីវិតដែលសមស្របដល់ជនរងគ្រោះ ។

**៣- តាមសហគមន៍**

កិច្ចការពារនៅតាមសហគមន៍ គឺជាកិច្ចការពារនៅតាមវត្តអារាមព្រះពុទ្ធសាសនា ទីកន្លែងសាសនានានា ជាមួយក្រុមគ្រួសារបង្កើត និងសាច់ញាតិជនរងគ្រោះ ។

**ប្រការ ៤.-**

- ជនរងគ្រោះ គឺជាបុគ្គលទាំងឡាយណាដែលទទួលរងការបំពាន ការកេងប្រវ័ញ្ចដោយបុគ្គលម្នាក់ទៀត ឬដោយក្រុមមនុស្សដោយផ្ទាល់ ឬ ដោយប្រយោល សម្រាប់គោលដៅជួញដូរមនុស្ស

- អង្គការដែលផ្តល់សេវា ត្រូវចាត់វិធានការឱ្យបានហ្មឹងម៉ាត់ចំពោះភ្ញៀវ ឬអ្នកមកសួរសុខទុក្ខជនរងគ្រោះ គឺចាំបាច់ត្រូវបានវាយតម្លៃឱ្យបានហ្មត់ចត់មុនអនុញ្ញាតឱ្យជួបជនរងគ្រោះ និងត្រូវបានផ្តល់ព័ត៌មានឱ្យដឹងអំពីគោលនយោបាយ ដើម្បីការពារសិទ្ធិជនរងគ្រោះ

- ការវាយតម្លៃស្ថានភាពរាងកាយ ផ្លូវចិត្ត និងអារម្មណ៍របស់ជនរងគ្រោះ ត្រូវធ្វើឡើងជាទៀងទាត់ ដើម្បីធានាសុខុមាលភាព និងសុវត្ថិភាពផ្លូវកាយ និងផ្លូវចិត្តរបស់ជនរងគ្រោះ

- ការវាយតម្លៃទូលំទូលាយអំពីភាពប្រឈមនឹងគ្រោះថ្នាក់ និងសន្តិសុខ ត្រូវធ្វើឡើងដោយសហការជាមួយគ្រួសារ សហគមន៍ និងភាគីដែលពាក់ព័ន្ធផ្សេងទៀត នៅមុនពេលធ្វើសមាហរណកម្មដោយកត់សម្គាល់ថាជនរងគ្រោះអាចនឹងត្រូវសមាហរណកម្មទៅក្នុងគ្រួសារ និងសហគមន៍ដើមវិញក៏បាន ឬ ក្រៅពីគ្រួសារ និងសហគមន៍ដើមក៏បាន

- ការវាយតម្លៃទូទៅ អំពីបញ្ហាដែលអាចកើតមានឡើងក្នុងបរិវេណមណ្ឌល ត្រូវរៀបចំធ្វើឡើងជាប្រចាំឆ្នាំ

- ដំណើរការជ្រើសរើសបុគ្គលិក ត្រូវមានការរៀបចំធ្វើការប៉ាន់ប្រមាណលម្អិត អំពីភាពសមស្របដែលរួមមាន ការពិនិត្យមើលឯកសារថ្កោលទោសសម្រាប់បុគ្គលិកទាំងអស់ ដែលត្រូវធ្វើការទំនាក់ទំនងការងារជាមួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស

- កន្លែងដែលផ្តល់ការថែទាំដល់ជនរងគ្រោះត្រូវមានពិធីការល្អ និងវិធានការលឿនរហ័ស និងអនុវត្តមានប្រសិទ្ធភាព សម្រាប់ពេលដែលជនរងគ្រោះបាត់ខ្លួន ឬ ចាកចេញពីកន្លែងដោយមិនបានប្រាប់ដំណឹងដល់បុគ្គលិក។

**២- សិទ្ធិទទួលបានអត្តសញ្ញាណបុគ្គល**

- មនុស្សម្នាក់ជាសំខាន់បំផុត ត្រូវទទួលបានការទទួលស្គាល់ថាជាបុគ្គលធម្មតា ឬ សាមញ្ញម្នាក់នៅមុនពេលទទួលស្គាល់ថា ជាជនរងគ្រោះ

- ជំនឿ តម្លៃ ឥរិយាបថ អត្តសញ្ញាណ និងបទពិសោធន៍ជាលក្ខណៈបុគ្គលរបស់ជនរងគ្រោះ ត្រូវតែទទួលបានការគិតគូរពិចារណា និងការគោរព

- ទស្សនៈជាលក្ខណៈបុគ្គលឯកជនរបស់ជនរងគ្រោះ ការបកស្រាយអំពីការរងនូវអំពើជួញដូរ និងវិធីដែលត្រូវជ្រើសរើស យកការស្តារនីតិសម្បទាដែលជនរងគ្រោះយល់ថាល្អបំផុតនោះ ត្រូវគាំទ្រទស្សនៈ និងគោរពជំហររបស់ជនរងគ្រោះ ។

**៣- សិទ្ធិទទួលបានឯកជនភាព និងការរក្សាការសម្ងាត់**

- អ្នកផ្តល់សេវាត្រូវយល់ពីភាពខុសគ្នា រវាងព័ត៌មានឯកជន ព័ត៌មានសម្ងាត់ និងព័ត៌មានទូទៅ

- មិនត្រូវផ្តល់ព័ត៌មានសម្ងាត់របស់ជនរងគ្រោះ ដោយគ្មានការយល់ព្រមពីជនរងគ្រោះឡើយ ។ ក្នុងករណីចាំបាច់ដែលត្រូវផ្តល់ព័ត៌មានទៅអ្នកណាម្នាក់ ឬអង្គការណាមួយ ត្រូវជូនដំណឹងឱ្យជនរងគ្រោះបានដឹងអំពីអ្នកដែលនឹងទទួលព័ត៌មាន និងមូលហេតុនៃការផ្តល់ព័ត៌មានឱ្យបានជាក់លាក់

**៦- សិទ្ធិទទួលបានសេវា**

- ជនរងគ្រោះទាំងអស់មានសិទ្ធិទទួលបានសេវានានា ដូចជាសេវាផ្នែកចិត្តសាស្ត្រ ផ្នែកច្បាប់ វេជ្ជសាស្ត្រ សាសនា សេដ្ឋកិច្ចសង្គម និងការបណ្តុះបណ្តាលវិជ្ជាជីវៈ នៅគ្រប់ដំណាក់កាលនៃដំណើរការផ្តល់ជំនួយដល់ជនរងគ្រោះ

- ស្ថាប័នរដ្ឋ សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវសហការដើម្បីជួយជនរងគ្រោះឱ្យទទួលបានសេវាដែលមុខសញ្ញារងគ្រោះត្រូវការ

- អ្នកផ្តល់សេវាត្រូវពិគ្រោះយោបល់ជាមួយជនរងគ្រោះ នៅក្នុងដំណើរការគ្រប់គ្រងករណី ដើម្បីធានាដោះស្រាយ រវាងតម្រូវការរបស់ជនរងគ្រោះនិងការផ្តល់សេវាឱ្យបានស៊ីសង្វាក់គ្នា និងសមស្រប ។

**៧- សិទ្ធិទទួលបានយុត្តិធម៌**

- ត្រូវពន្យល់អំពីនីតិវិធីដោះស្រាយឱ្យមានភាពយុត្តិធម៌ដល់ជនរងគ្រោះ ក្នុងលក្ខណៈមួយដែលងាយស្រួលយល់

- ត្រូវផ្តល់ជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ ដល់ជនរងគ្រោះតាមភាពចាំបាច់របស់ជនរងគ្រោះ

- ត្រូវផ្តល់សិទ្ធិអំណាចដើម្បីឱ្យជនរងគ្រោះមានជម្រើសសម្រេច ថាតើគេចង់ដោះស្រាយតាមប្រព័ន្ធតុលាការដែរ ឬ ទេ

- ជនរងគ្រោះត្រូវទទួលបានឱកាសចូលរួម និងស្តាប់ការជំនុំជំរះរបស់តុលាការ និងធ្វើការសម្រេចចិត្ត ប្តឹង ឬ មិនប្តឹងឧទ្ធរណ៍

- កុមាររងគ្រោះត្រូវមានមេធាវីការពារក្តីជាការចាំបាច់ ដែលត្រូវបានចាត់តាំងឱ្យមានវត្តមានក្នុងបញ្ហាទាំងឡាយដែលទាក់ទងនឹងច្បាប់ ដើម្បីធានាឧត្តមប្រយោជន៍កុមារ ។

**៨- សិទ្ធិទទួលបានប្រក្រតីភាព**

- ត្រូវពង្រឹងលទ្ធភាពរបស់ជនរងគ្រោះ ដើម្បីធ្វើសមាហរណកម្មប្រកបដោយប្រសិទ្ធភាពទៅក្នុងសង្គម និងគ្រួសារវិញ ដោយផ្តល់ឱ្យពួកគេនូវសេវា និងការថែទាំ ដែលចាំបាច់នានាក្នុងអំឡុងពេលដំណើរការជួយដល់ជនរងគ្រោះ

- អ្នកដែលធ្វើការជាមួយជនរងគ្រោះ ត្រូវកាត់បន្ថយឱ្យបាននូវភាពអាម៉ាស់ ការលម្អៀង ទាក់ទិននិន្នាការ វប្បធម៌ និងការរើសអើង ដែលជនរងគ្រោះអាចនឹងជួបប្រទះ

- អ្នកធ្វើការជាមួយជនរងគ្រោះ មិនត្រូវបង្ហាញអាកប្បកិរិយារើសអើង ស្អប់ខ្ពើម ចំពោះជនរងគ្រោះឡើយ

- អ្នកផ្តល់សេវាត្រូវផ្តល់ជំនួយ និងចាត់វិធានការជាក់ស្តែង ដើម្បីជួយដល់ជនរងគ្រោះក្នុងការធ្វើសមាហរណកម្មទៅក្នុងសហគមន៍តាមការជ្រើសរើសរបស់សាមីខ្លួន

- ប្រសិនបើពុំមានអ្វីប៉ះពាល់ដល់សុវត្ថិភាពទេ ជនរងគ្រោះត្រូវតែទទួលបានឱកាសទំនាក់ទំនងជាមួយក្រុមគ្រួសារសាច់ញាតិ ក្នុងអំឡុងពេលដែលពួកគេស្ថិតក្រោមដំណើរការស្តារ ។

**៩- សិទ្ធិចូលរួម**

- ត្រូវពង្រឹងលទ្ធភាពដល់ជនរងគ្រោះ ដើម្បីពួកគេអាចក្លាយជាអ្នកចូលរួមយ៉ាងសកម្ម នៅក្នុងគ្រប់ទិដ្ឋភាព នៃដំណើរការផ្តល់ជំនួយដល់ជនរងគ្រោះ

- មណ្ឌលអាចរក្សាទុកកុមាររងគ្រោះផ្ទុយពីឆន្ទៈរបស់សាម៉ីខ្លួនបាន ក្នុងករណីដើម្បីធានាសុវត្ថិភាព និង ដើម្បីការពារឧត្តមប្រយោជន៍កុមារ ។ តែទោះជាយ៉ាងណាក៏ដោយសម្រាប់កុមាររងគ្រោះ ត្រូវមានវិធានការនានា ក្នុងការកំណត់អត្តសញ្ញាណគ្រួសារឱ្យបានរហ័ស ហើយត្រូវសមាហរណកម្មកុមារជូនក្រុមគ្រួសារគេវិញ ក្នុងករណី ពិនិត្យឃើញថាកុមារមានសុវត្ថិភាពបរិបូរណ៍

- ក្នុងករណីជនរងគ្រោះមិនដឹងពីអាយុពិតប្រាកដ ប៉ុន្តែសង្ស័យថាជាកុមារ ត្រូវចាត់ទុកជនរងគ្រោះនោះ ជាកុមារ ហើយសេរីភាពបម្លាស់ទីត្រូវកំណត់ក្នុងលក្ខណៈជាកុមារ ។

ជារួមអាទិភាពនៃសេរីភាព ធ្វើការបម្លាស់ទី ត្រូវឈរលើគោលការណ៍កំណត់អាយុពិតប្រាកដរបស់ ជនរងគ្រោះ ។

**ប្រការ ៧.–**

ដំណើរការគ្រប់គ្រងករណី ចាប់ផ្តើមឡើងនៅពេលដែលជនរងគ្រោះ ឬ ជនដែលសង្ស័យថាអាចរងគ្រោះ ដោយអំពើជួញដូរមនុស្ស ត្រូវបានកំណត់អត្តសញ្ញាណ បន្តរហូតដល់បិទករណី ។ ដំណើរការគ្រប់គ្រងករណីផ្តល់ នូវលក្ខខណ្ឌសំខាន់ចាំបាច់សម្រាប់អ្នកផ្តល់សេវាធ្វើផែនការសកម្មភាពដើម្បីពង្រីក ពង្រឹងប្រសិទ្ធភាពជួយជនរងគ្រោះ ។ ដំណាក់កាលក្នុងដំណើរការគ្រប់គ្រងករណី មិនចាំបាច់ធ្វើតាមលំដាប់លំដោយដែលបានកំណត់ក្នុងផែនការនោះទេ ត្រូវធ្វើ តាមសភាពការណ៍ ជាក់ស្តែង គឺអនុវត្តដំណើរការតាមជំហានម្តងមួយៗ និងអាចគួបផ្សំជំហានជាច្រើនក្នុងពេលតែមួយ ។ ដំណាក់កាលក្នុង ដំណើរការគ្រប់គ្រងករណីរួមមាន : ការកំណត់អត្តសញ្ញាណជនរងគ្រោះ អន្តរាគមន៍វិបត្តិ ការបញ្ជូន ការទទួល ផែនការករណី ការប៉ាន់ប្រមាណ ការស្តារទៅកាន់ភាពប្រក្រតី សមាហរណកម្ម ការតាមដាន និងបិទករណី ។ នៅក្នុងដំណើរការនៃការគ្រប់គ្រងករណីតាំងពីដើមរហូតដល់បញ្ចប់ សិទ្ធិជាមូលដ្ឋានទាំងអស់របស់ជនរងគ្រោះ ដែលមាន ចែងក្នុងជំពូកទី២ នៃបទដ្ឋានអប្បបរមានេះ សម្រាប់អ្នកផ្តល់សេវាទាំងអស់ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ដំណើរការគ្រប់គ្រងករណីរួមមាន :

**១- ការកំណត់អត្តសញ្ញាណជនរងគ្រោះ**

- ការសម្ភាសន៍ជនរងគ្រោះត្រូវរៀបចំធ្វើនៅកន្លែងដែលមានសុវត្ថិភាព

- អ្នកផ្តល់សេវាមិនត្រូវឱ្យជនរងគ្រោះ និងជនសង្ស័យ ឬ ជនល្មើស មានការជួបប្រាស្រ័យទាក់ទង ដោយផ្ទាល់ឡើយ

- ក្នុងករណីមានមន្ទិលសង្ស័យថាជនណាម្នាក់ជាជនរងគ្រោះពិត ឬ មិនពិតនោះ ត្រូវចាត់ទុកជន នោះជាជនរងគ្រោះ ហើយត្រូវផ្តល់ការគាំទ្រនិងជួយសេវាសមស្រប រហូតដល់ពេលមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ជននោះមិនមែនជាជនរងគ្រោះ

- ជនរងគ្រោះដែលមិនទាន់ដឹងអាយុពិតប្រាកដ ប៉ុន្តែសង្ស័យថាជាកុមារ ត្រូវចាត់ទុកជនរងគ្រោះនោះជា កុមារ ហើយដំណើរការកំណត់អត្តសញ្ញាណ និងការសម្ភាសន៍ ត្រូវអនុវត្តតាម ( អនុសញ្ញាស្តីពីសិទ្ធិកុមារ ) និងត្រូវ

- កិច្ចអន្តរាគមន៍វិបត្តិ ចាំបាច់ត្រូវមានមន្ត្រី បុគ្គលិកដែលពាក់ព័ន្ធក្នុងការអនុវត្តនីតិវិធីផែនការករណី ពិសេស ត្រូវសហការរួមជាមួយ ៖ មន្ត្រីនគរបាល មន្ត្រីសង្គមកិច្ច អ្នកផ្តល់សេវារបស់អង្គការមិនមែនរដ្ឋាភិបាល អ្នកផ្តល់សេវាឯកជន និងមន្ត្រីស្ថានទូត និង/ឬមន្ត្រីផ្នែកអន្តោប្រវេសន៍ " ក្នុងករណីជនរងគ្រោះជាជនបរទេស "។

**៣- ការបញ្ជូន**

- ការបញ្ជូនត្រូវផ្អែកលើការសម្រេចចិត្តរបស់ជនរងគ្រោះ ហើយត្រូវធ្វើនៅពេលណាមួយ ក្នុងដំណាក់កាលនានានៃដំណើរការជួយជនរងគ្រោះតាមសំណូមពររបស់សាមីខ្លួន

- អ្នកផ្តល់សេវាត្រូវមាន បញ្ជីឈ្មោះ ទីកន្លែង និងដៃគូដែលអាចរកសេវាបញ្ជូនជនរងគ្រោះដោយសុវត្ថិភាព បញ្ជីនេះត្រូវធ្វើបច្ចុប្បន្នភាពឱ្យបានទៀងទាត់ និងហ្មត់ចត់

- នៅក្នុងអំឡុងពេលបញ្ជូន អ្នកផ្តល់ និងអ្នកទទួលត្រូវសហការជាមួយគ្នា ដោយត្រូវចាត់ទុកសេចក្តីត្រូវការរបស់ជនរងគ្រោះ ជាអាទិភាព

- នៅពេលបញ្ជូនជនរងគ្រោះ អ្នកបញ្ជូនត្រូវផ្តល់ព័ត៌មានទាំងអស់ដែលពាក់ព័ន្ធករណីរបស់ជនរងគ្រោះដល់អ្នកផ្តល់សេវា

- ការមិនពេញចិត្ត និងការរើសអើងគ្រប់ប្រភេទចំពោះជនរងគ្រោះ មិនអាចយកធ្វើជាហេតុផលសម្រាប់ការបញ្ជូន ឬ បដិសេធការបញ្ជូនជនរងគ្រោះទៅរកសេវា ឬ ជំនួយផ្សេងៗបានឡើយ

- អ្នកផ្តល់សេវាត្រូវទទួលស្គាល់នូវកម្រិតសេវារបស់ខ្លួន ហើយត្រូវបញ្ជូនជនរងគ្រោះទៅរកសេវាផ្នែកវេជ្ជសាស្ត្រ ចិត្តសាស្ត្រ និងធនធានអភិវឌ្ឍន៍មុខជំនាញនៅតាមមណ្ឌល ដោយផ្អែកលើសេចក្តីត្រូវការរបស់ជនរងគ្រោះ ។

**៤- ការទទួល**

- ដំបូងបង្អស់ អ្នកផ្តល់សេវាត្រូវធ្វើឱ្យជនរងគ្រោះមានអារម្មណ៍ទទួលបានសុវត្ថិភាព និងសន្តិសុខល្អ ហើយត្រូវព្យាយាមកសាងទំនាក់ទំនងជាមួយជនរងគ្រោះឱ្យបានជិតស្និទ្ធ

- ត្រូវប្រើយុទ្ធសាស្ត្រដែលផ្អែកលើមូលដ្ឋានយេនឌ័រ នៅពេលទទួលជនរងគ្រោះ ជាស្ត្រីត្រូវទទួលស្វាគមន៍ដោយស្ត្រី បើបុរសត្រូវទទួលស្វាគមន៍ដោយបុរស លើកលែងតែក្នុងករណីដែលកាលៈទេសៈពិសេសរបស់ជនរងគ្រោះទាមទារឱ្យមានការរៀបចំផ្សេងពីនេះ

- អ្នកផ្តល់សេវាត្រូវបង្ហាញជនរងគ្រោះ ឱ្យស្គាល់កន្លែងចាំបាច់នានានៅជុំវិញខ្លួនគេ ក្នុងនោះរាប់ទាំងការបង្ហាញបន្ទប់ទឹក និងបន្ទប់គេងជាដើម

- អ្នកផ្តល់សេវាត្រូវណែនាំជនរងគ្រោះឱ្យបានយល់អំពីគោលបំណង តួនាទីភារកិច្ចរបស់ខ្លួន និងអំពីគោលការណ៍ វិធានការ បទបញ្ជាដែលចាំបាច់នានា ក្នុងនោះរាប់ទាំងបទបញ្ជាផ្ទៃក្នុង ស្តីពីរបៀបរបបក្នុងការស្នាក់នៅក្នុងបរិវេណដែលខ្លួនគ្រប់គ្រង

- អ្នកផ្តល់សេវា ត្រូវរៀបចំកន្លែងទទួលជនរងគ្រោះ ដែលអាចទទួលបានផាសុកភាព តាមដែលលទ្ធភាពអាចធ្វើទៅបាន និងត្រូវទុកលទ្ធភាពឱ្យជនរងគ្រោះសម្របខ្លួនទៅនឹងបរិយាកាសជុំវិញកន្លែងស្នាក់នៅថ្មីជាមុនសិន មុននឹងធ្វើការសម្ភាសន៍។

- ការប៉ាន់ប្រមាណ និងការសម្ភាសន៍ ត្រូវផ្ដោតទៅលើមុខសញ្ញាជនរងគ្រោះ។ ជនរងគ្រោះត្រូវតែដឹងច្បាស់អំពីបំណងនៃការប៉ាន់ប្រមាណ និងយល់ស្របចំពោះវិធីសាស្ត្រនៃការប៉ាន់ប្រមាណ

- លទ្ធផលពីការប៉ាន់ប្រមាណ ត្រូវយកទៅប្រើប្រាស់ដើម្បីកំណត់សេវា និងការគាំទ្រដល់ជនរងគ្រោះ និងអាចប្រើជាព័ត៌មានសម្រាប់ធ្វើផែនការករណី ។

**៧- ការស្ដារ**

- អ្នកផ្ដល់សេវាត្រូវតែទទួលស្គាល់ថា សិទ្ធិបុគ្គលម្នាក់ៗមានសភាពខុសៗគ្នា ដូច្នេះជនរងគ្រោះគ្រប់រូបមានសិទ្ធិទទួលបានការស្ដារ ដើម្បីឱ្យវិលទៅរកភាពធម្មតាខុសៗគ្នាទៅតាមជំហានផ្ទាល់ខ្លួនរបស់ជនរងគ្រោះម្នាក់ៗ

- ជនរងគ្រោះ ត្រូវបានពង្រឹងលទ្ធភាព និងសមត្ថភាពនៅក្នុងដំណើរការតាំងពីដើមរហូតដល់បញ្ចប់នៃការស្ដារ និងមានសិទ្ធិសម្រេចចិត្ត ដោយការយល់ដឹងច្បាស់លាស់អំពីសេវានានា ដែលមានសារៈប្រយោជន៍ ឬ សមស្របបំផុត និងអំពីពេលវេលាដែលសាមីខ្លួនចង់ចូលរួមនៅក្នុងសកម្មភាពទាំងអស់នោះ

- ជនរងគ្រោះត្រូវបានផ្ដល់លទ្ធភាពក្នុងការទទួលបានសេវា និងសិទ្ធិក្នុងការទទួល ឬបដិសេធសេវាក្នុងនោះ រាប់បញ្ចូលទាំងសេវាវេជ្ជសាស្ត្រ សេវាចិត្តសាស្ត្រ សេវាផ្នែកច្បាប់ ការស្នាក់នៅ សេវាបំណិនជីវិត សកម្មភាពកម្សាន្ត និងសេវាផ្នែកសាសនា និង/ឬនៅទីកន្លែងសក្ការៈបូជាណាមួយ

- ត្រូវជួយគាំទ្រដល់ជនរងគ្រោះ នៅក្នុងការប្រាស្រ័យទាក់ទងគ្នា ជាមួយក្រុមគ្រួសារ និងសហគមន៍ដែលគេធ្លាប់រស់នៅឱ្យបានល្អប្រសើរឡើងវិញ តាមការវាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមទាំងឡាយដែលជនរងគ្រោះអាចជួបប្រទះ

- ជនរងគ្រោះត្រូវមានឱកាសដើម្បីប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ និងឱកាសក្នុងការចំណាយពេលវេលាពិចារណាដោយខ្លួនឯង ដើម្បីជួយរួមចំណែកដល់ដំណើរវិលត្រឡប់ទៅរកសភាពធម្មតាវិញរបស់ខ្លួន

- អ្នកផ្ដល់សេវាត្រូវធ្វើការស្ដារទំនុកចិត្តដល់ជនរងគ្រោះ តាមរយៈការកំណត់នូវភាពខ្លាំង និងការបង្ហាញពីអារម្មណ៍របស់ជនរងគ្រោះ

- ត្រូវផ្ដល់នូវសកម្មភាពណាដែលសមស្របនឹងអាយុ ដើម្បីជួយស្ដារជនរងគ្រោះ ពិសេសកុមារ ឱ្យបានឆាប់ជាសះស្បើយ ។

**៨- សមាហរណកម្ម**

- ជាយុទ្ធសាស្ត្រ ត្រូវផ្ដោតសំខាន់ទៅលើសិទ្ធិជនរងគ្រោះពេលធ្វើសមាហរណកម្មទៅកន្លែងនីមួយៗ និងនៅពេលវេលាណាមួយ អាស្រ័យលើការសម្រេចចិត្តរបស់ជនរងគ្រោះ។ អាចសមាហរណកម្មទៅគ្រួសារ និងសហគមន៍ដើម ឬ គ្រួសារ និងសហគមន៍ថ្មី

- តាមការស្នើសុំរបស់ជនរងគ្រោះ ការលើកកម្ពស់ការយល់ដឹង និងជំនួយ ត្រូវផ្ដល់ដល់សហគមន៍នៅមុន និងក្រោយពេលធ្វើសមាហរណកម្មរបស់ជនរងគ្រោះ

- ត្រូវផ្ដល់ការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈ ដែលរៀបចំឡើងសម្រាប់ការប្រើប្រាស់នៅក្នុងសហគមន៍ដែលជនរងគ្រោះត្រូវធ្វើសមាហរណកម្ម

- នៅមុនពេលបិទករណី អ្នកផ្តល់សេវាត្រូវត្រៀមលក្ខណៈគ្រប់គ្រាន់សម្រាប់ជនរងគ្រោះ ក្រុមគ្រួសារ និងសហគមន៍សម្រាប់ការបិទករណី ក្នុងនោះរាប់បញ្ចូលទាំងសភាពការណ៍ល្អ និងសភាពការណ៍មិនល្អដែលអាចកើតមាននៅក្នុងអំឡុងពេល ឬនៅក្រោយពេលបិទករណី

- មិនត្រូវប្រញាប់ប្រញាល់បិទករណី នៅពេលដែលជនរងគ្រោះមិនបានចូលរួមសហការ ប៉ុន្តែផ្ទុយទៅវិញត្រូវព្យាយាមស្វែងយល់អំពីមូលហេតុ ដែលជនរងគ្រោះមិនព្រមសហការ នេះគឺជាសញ្ញាមួយអាចកត់សម្គាល់បានថាមានបញ្ហាទើបកើតឡើងថ្មីទៀតចំពោះជនរងគ្រោះ ដូច្នេះអ្នកផ្តល់សេវាត្រូវពិនិត្យស្ថានភាព និងវាយតម្លៃអំពីជំហានអ្វីខ្លះ ដែលត្រូវអនុវត្តបន្ទាប់ចំពោះជនរងគ្រោះរូបនេះ

- ក្នុងករណីអ្នកផ្តល់សេវា បានបិទករណីណាមួយដោយមិនបានទទួលជោគជ័យ ឬមិនបានទទួលលទ្ធផលគួរជាទីពេញចិត្ត អ្នកផ្តល់សេវាត្រូវប្រើប្រាស់ករណីនេះជាបទពិសោធន៍សម្រាប់ការរៀនសូត្រ និងធ្វើការវិភាគករណីនេះ ដើម្បីកំណត់ឱ្យបាននូវចំណុចខ្វះខាតសម្រាប់កែលម្អនៅពេលអនុវត្តក្នុងការផ្តល់សេវាលើកក្រោយៗទៀត។

**ប្រការ ៨.–**

ដើម្បីជួយជនរងគ្រោះដោយអំពើជួញដូរមនុស្សឱ្យទទួលបានដោយប្រសិទ្ធភាព និងជោគជ័យ អ្នកផ្តល់សេវាគ្រប់រូបចាំបាច់ត្រូវមានសុខភាព ផ្លូវកាយ និងចិត្តរឹងប៉ឹង មានប្រាជ្ញាឈ្លាសវៃ ហេតុនេះអ្នកផ្តល់សេវាត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម ៖

**១- ការថែទាំខ្លួនសម្រាប់អ្នកផ្តល់សេវា**

- អ្នកផ្តល់សេវាត្រូវដឹងថា ខ្លួនអាចធ្វើជាអ្នកផ្តល់សេវាដែលមានប្រសិទ្ធភាពល្អ លុះត្រាណាតែខ្លួនមានសុខភាពផ្លូវចិត្ត ផ្លូវកាយ និងផ្លូវអារម្មណ៍ និងស្ថានភាពជីវភាពក្នុងសង្គមល្អជាមុនសិន។ ដូច្នេះការទទួលខុសត្រូវចម្បងរបស់អ្នកផ្តល់សេវា គឺថែទាំខ្លួនឯងជាគំរូដល់ជនរងគ្រោះ

- អ្នកផ្តល់សេវាត្រូវមានការប្រុងប្រយ័ត្នគ្រប់ករណី ក្នុងពេលធ្វើការជាមួយជនរងគ្រោះ និងត្រូវច្បាស់ក្នុងចិត្តថា ខ្លួនមានលទ្ធភាពគ្រប់គ្រាន់សម្រាប់ចាត់វិធានការសមស្រប ដើម្បីកិច្ចការពារសុវត្ថិភាពផ្លូវកាយ និងផ្លូវចិត្តដល់ជនរងគ្រោះ

- អ្នកផ្តល់សេវាត្រូវដឹងច្បាស់ពីអ្វីដែលធ្វើឱ្យមានការប៉ះទង្គិចពីជនរងគ្រោះ និងអ្វីដែលធ្វើឱ្យអ្នកផ្តល់សេវាផ្ទាល់មានភាពតានតឹងផ្លូវចិត្ត ដែលអាចទទួលពីជនរងគ្រោះ ហើយអ្នកផ្តល់សេវាក៏ត្រូវដឹង អំពីវិធានការបង្ការនានាដែលអាចអនុវត្ត ដើម្បីកាត់បន្ថយបញ្ហាប្រឈមទាំងនេះឱ្យមានប្រសិទ្ធភាព

- អ្នកផ្តល់សេវាត្រូវដឹង និងប្រុងប្រយ័ត្នចំពោះភាពតានតឹងផ្លូវចិត្ត និងការនឿយហត់ផ្លូវចិត្តរបស់ខ្លួនផ្ទាល់ ហើយអ្នកផ្តល់សេវាត្រូវដឹងអំពីបច្ចេកទេស និងវិធានការផ្សេងៗ ដើម្បីកាត់បន្ថយភាពតានតឹងខាងផ្លូវចិត្ត និងវិធីធ្វើឱ្យមានសុខភាពល្អ ក្នុងការដោះស្រាយបញ្ហាតានតឹងផ្លូវចិត្ត និងការឈឺចាប់ផ្នែកអារម្មណ៍របស់ខ្លួន

- អ្នកផ្តល់សេវាត្រូវចាត់វិធានការ ដើម្បីផ្តល់ការគាំទ្រខាងផ្លូវចិត្តដល់ជនរងគ្រោះ ដោយមិនធ្វើឱ្យអារម្មណ៍របស់ខ្លួន ចូលលាយឡំ និងពាក់ព័ន្ធនឹងបញ្ហារបស់ជនរងគ្រោះ។ អ្នកផ្តល់សេវាត្រូវរក្សានូវភាពដាច់ដោយឡែកពីគ្នារវាងអ្នកផ្តល់សេវា និងបញ្ហារបស់ខ្លួន

**ប្រការ ១០.-**

- នាយក នាយិការបស់អង្គការដែលផ្តល់សេវាជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវទទួលខុសត្រូវផ្សព្វផ្សាយ និងអប់រំបុគ្គលិកអំពីសេចក្តីប្រកាសសាកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ គោលនយោបាយ និងបទដ្ឋានអប្បបរមា សម្រាប់កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស

- នាយក នាយិការបស់អង្គការដែលធ្វើការជាមួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវគោរព និងអនុវត្តឱ្យស្របតាមសេចក្តីប្រកាសសាកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ គោលនយោបាយ និងបទដ្ឋានអប្បបរមា សម្រាប់កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្សឱ្យបានល្អប្រសើរ

- អ្នកផ្តល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវគោរព និងអនុវត្តអោយមានប្រសិទ្ធភាពនូវសេចក្តីប្រកាសសាកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ គោលនយោបាយ និងបទដ្ឋានអប្បរមាសម្រាប់កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស

- អង្គការមិនមែនរដ្ឋាភិបាលដែលអនុវត្តនូវកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីអនុវត្តកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្សស្របតាមច្បាប់ជាធរមាន

- ថ្នាក់ដឹកនាំ និងមន្ត្រីនាយកដ្ឋានសុខុមាលភាពសង្គម និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ត្រូវធានាផ្សព្វផ្សាយអំពីសេចក្តីប្រកាសសាកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ គោលនយោបាយ និងបទដ្ឋានអប្បបរមា សម្រាប់កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ឱ្យបានទូលំទូលាយ

- ថ្នាក់ដឹកនាំ និងមន្ត្រីនាយកដ្ឋានសុខុមាលភាពសង្គម និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ត្រូវស្វែងយល់ និងចាត់តាំងអនុវត្តឱ្យមានប្រសិទ្ធភាពអំពីគោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

**ប្រការ ១១.-**

ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវមានសំណុំឯកសារផ្ទាល់ខ្លួន ហើយសំណុំឯកសារនេះត្រូវ ថែរក្សាដោយអ្នកផ្តល់សេវា ដែលទទួលខុសត្រូវលើសេវាទីកន្លែងស្នាក់នៅរបស់ជនរងគ្រោះ ។ សំណុំឯកសាររបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវមានព័ត៌មានដូចខាងក្រោម :

១- ឈ្មោះពេញរបស់ជនរងគ្រោះ និងឈ្មោះផ្សេងទៀត ដែលធ្លាប់ប្រើ រូបថត ភេទ ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត ។

២- កាលបរិច្ឆេទ អាសយដ្ឋានរស់នៅរបស់ជនរងគ្រោះទាំងមុន និងក្រោយពេលរងគ្រោះ ព្រមទាំងមូលហេតុដែលទទួលរងគ្រោះ ។

៣- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត អាសយដ្ឋាន និងមុខរបររបស់ឪពុកម្តាយ បងប្អូនបង្កើត និងសាច់ញាតិជិតស្និទ្ធរបស់ជនរងគ្រោះ ។

## ជំពូកទី ៤

## ការត្រួតពិនិត្យកិច្ចការពារសិទ្ធជនរងគ្រោះដោយអំពើជួញដូរមនុស្ស

**ប្រការ ១៣.–**

- មន្ត្រីសង្គមកិច្ច បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ដែលអនុវត្តកម្មវិធីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវទទួលខុសត្រូវលើការតាមដាន ត្រួតពិនិត្យការថែទាំជនរងគ្រោះជាប្រចាំ និងជាបន្តបន្ទាប់ ដើម្បីសហការ លើកទឹកចិត្ត ជំរុញឱ្យអ្នកផ្តល់សេវាកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្សទាំងនោះ អនុវត្តស្របតាមបទដ្ឋានអប្បបរមានេះ

- ត្រូវវាយតម្លៃការធ្វើសមាហរណកម្មឱ្យបានទៀងទាត់ ដើម្បីធានាឱ្យជនរងគ្រោះមានការវិវត្តន៍រីកចម្រើនគ្រប់ផ្នែក ។ ការវាយតម្លៃនេះរួមមានការពិនិត្យសំណុំឯកសារ ការចុះដល់កន្លែងរស់នៅ និងការសម្ភាសន៍ជាមួយគ្រួសារ អ្នកជិតខាង អាជ្ញាធរដែនដី និងជនរងគ្រោះផ្ទាល់

- បន្ទាប់ពីបានវាយតម្លៃ ក្នុងករណីលទ្ធផលបង្ហាញថា គ្រួសារ ឬ សាច់ញាតិ ដែលមិនបានគោរពសិទ្ធិជនរងគ្រោះនោះទេ អ្នកគ្រប់គ្រងដែលទទួលសេវាការពារសិទ្ធិជនរងគ្រោះ ត្រូវសុំការផ្លាស់ប្តូរជនរងគ្រោះទៅកន្លែងមួយផ្សេងទៀត ដែលបានធ្វើការប៉ាន់ប្រមាណរួចជាស្រេច ឬ ទៅរស់នៅក្នុងទម្រង់មួយផ្សេងទៀតដែលអាចធានាសុវត្ថិភាពជនរងគ្រោះបានល្អប្រសើរ

- នាយកដ្ឋានសុខុមាលភាពសង្គម មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ត្រូវចុះត្រួតពិនិត្យអ្នកផ្តល់សេវាពីការអនុវត្តន៍បទដ្ឋានអប្បបរមានេះ យ៉ាងតិចម្តងក្នុងមួយឆ្នាំ ។ ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តបទដ្ឋានអប្បរមា សម្រាប់កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវអនុវត្តជាជំហានៗឱ្យមានប្រសិទ្ធភាពចំពោះកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

នាយកដ្ឋានសុខុមាលភាពសង្គម និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ត្រូវចាត់តាំងអនុវត្តតាមដំណាក់កាលដូចខាងក្រោម :

១- ធ្វើការផ្សព្វផ្សាយ បណ្តុះបណ្តាលប្រកាសស្តីពីបទដ្ឋានអប្បបរមា សម្រាប់កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

២- រៀបចំធ្វើការពិនិត្យ និងវាយតម្លៃ ចំពោះអង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់សេវាកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្នុងជំហានអប់រំណែនាំ លើកសរសើរ និង/ឬបន្តចុះអនុស្សារណៈ។

៣- ត្រួតពិនិត្យ និងវាយតម្លៃ អ្នកអនុវត្តន៍កម្មវិធីផ្តល់សេវាការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្សរបស់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងសមត្ថកិច្ច របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។ ក្នុងករណីអ្នកផ្តល់សេវាការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស មិនបានអនុវត្តតាមបទដ្ឋានអប្បបរមានេះ មន្ត្រីដែលចុះធ្វើការត្រួតពិនិត្យវាយតម្លៃ ត្រូវជូនដំណឹងទៅអ្នកផ្តល់សេវាទាំងនោះ ដើម្បីឱ្យធ្វើការកែលម្អក្នុងរយៈពេល ៣ ខែ មុនពេលចុះត្រួតពិនិត្យម្តងទៀត។

របស់ពួកគេ មិនអាចគេចផុតពីការផ្តន្ទាទោសបានឡើយ ។ យើងទាំងអស់គ្នាដឹងហើយថា ការជួញដូរមនុស្ស គឺជាឧក្រិដ្ឋកម្មគ្មានព្រំដែន ដូច្នេះហើយដើម្បីប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មនេះឱ្យបានប្រសិទ្ធភាព ចាំបាច់យើងត្រូវមានរចនាសម្ព័ន្ធ និងដំណើរការផ្នែកច្បាប់ដែលអាចដោះស្រាយចរិតលក្ខណៈឆ្លងដែន នៃឧក្រិដ្ឋកម្មនេះ ។

ចំពោះកិច្ចការពារសិទ្ធិជនរងគ្រោះ និងសិទ្ធិមនុស្សគឺ អនុវត្តទូទៅចំពោះមនុស្សគ្រប់រូប ក្នុងនោះរាប់បញ្ចូលទាំងជនរងគ្រោះនៃអំពើជួញដូរមនុស្សផងដែរ ។ យើងបានដឹងហើយថា ជនរងគ្រោះនៃអំពើជួញដូរមនុស្ស គឺជាជនរងគ្រោះនៃឧក្រិដ្ឋកម្មអន្តរជាតិ មិនមែនជាអន្តោប្រវេសន៍ខុសច្បាប់ទេ បើទោះបីជាស្ថានភាពរបស់ពួកគេអាចនឹងស្រដៀងគ្នា ក៏ដោយ ហើយក៏មិនមែនជាឧក្រិដ្ឋជននោះទេ ប៉ុន្តែពួកគេគឺជាបុគ្គលដែលមានសិទ្ធិក្នុងការទទួលបាននូវការគោរព និងត្រូវផ្តល់យុត្តិធម៌ និងសិទ្ធិក្នុងការកំណត់នូវអនាគតរបស់ពួកគេដោយគ្មានការរើសអើង ។ ពួកគេសក្តិសមនឹងទទួលបានការអាណិតអាសូររបស់យើង និងការចាត់វិធានការបន្ទាន់ពីរដ្ឋាភិបាលរបស់យើង ដើម្បីជួយសម្រាលទុក្ខលំបាករបស់ពួកគេ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានយកចិត្តទុកដាក់បង្កើតឱ្យមានការិយាល័យប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្ម ចំណុះនាយកដ្ឋានសុខុមាលភាពសង្គម និងរៀបចំប្រកាសលេខ ១២៨ ស.អ.យ. ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការបង្កើតមណ្ឌលសំចតប៉ោយប៉ែត ដើម្បីទទួលនិងធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរ និងកុមារងាយរងគ្រោះផ្សេងទៀត ដែលវិលត្រឡប់ពីប្រទេសថៃ និងវៀតណាមទៅរួមរស់ជាមួយគ្រួសារ ឬសហគមន៍វិញ ។ ក្រសួងក៏បានចេញសេចក្តីណែនាំលេខ ០០៩ ស.អ.យ. ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៧ ស្តីពីការងារសមាហរណកម្ម និងតាមដាន ក្រុមជនរងគ្រោះដែលបានស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ និងអង្គការ មិនមែនរដ្ឋាភិបាល ព្រមទាំងបានចុះអនុស្សារណៈ ស្តីពីការយោគយល់គ្នាជាមួយដៃគូវៀតណាម និងថៃ ដើម្បីបង្ក្រាប ឧក្រិដ្ឋកម្មជួញដូរមនុស្ស និងសង្គ្រោះជនរងគ្រោះដោយអំពើជួញដូរមនុស្សឆ្លងដែន ។

គោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្សជាជំហានថ្មីនៃការអនុវត្តសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ទន្ទឹមនឹងនោះក៏មានកិច្ចការមួយចំនួនបាននិងកំពុងរៀបចំជាបន្តបន្ទាប់ដូចជា ÷

- ចាត់វិធានការដើម្បីផ្តល់សច្ចាប័នចំពោះសន្ធិសញ្ញា ស្តីពីការផ្តល់ជំនួយផ្នែកច្បាប់ទៅវិញទៅមក សម្របសម្រួលដល់ការឆ្លើយតបផ្នែកច្បាប់រវាងបណ្តាប្រទេសក្នុងសមាគម ASEAN ។
- ពង្រីក ពង្រឹង និងតាមដានការអនុវត្តអនុស្សារណៈនៃការយោគយល់គ្នារវាងបណ្តាប្រទេសជិតខាង ដើម្បីបង្ក្រាបឧក្រិដ្ឋជន និងសង្គ្រោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។
- ប្រមូលផ្តុំអ្នកជំនាញរបស់រាជរដ្ឋាភិបាល អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីធានាបាននូវជំនាញ និងការឆ្លើយតបប្រកបដោយតុល្យភាព និងការគិតគូរហ្មត់ចត់ចំពោះផ្នែកផ្សេងៗនៃបញ្ហាជួញដូរមនុស្ស ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្តេជ្ញាអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមានេះឱ្យក្លាយទៅជាសកម្មភាពជាក់ស្តែង ប្រកបដោយតម្លាភាពប្រសិទ្ធភាពខ្ពស់ ពិសេសដើម្បីបង្ក្រាបឧក្រិដ្ឋកម្មជួញដូរមនុស្ស និងសង្គ្រោះជនរងគ្រោះដោយអំពើជួញដូរមនុស្សគ្រប់ៗរូបដោយគ្មានការរើសអើងឡើយ ។

# មាតិកា

## គោលនយោបាយស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស


**ទី១ : អារម្ភកថា** ............ ១

**ទី២ : ប្រកាស លេខ ៨៥២ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីការដាក់ឱ្យអនុវត្តគោលនយោបាយ ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស** ............ ៨

**ទី៣ : គោលនយោបាយ លេខ ០៦២ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស** ............ ១០

**I. គោលការណ៍រួម** ............ ១០

- អត្ថន័យនៃអំពើជួញដូរមនុស្ស ............ ១០
- គោលដៅនៃអំពើជួញដូរមនុស្ស ............ ១០
- សភាពការណ៍នៃអំពើជួញដូរមនុស្ស ............ ១០
- មូលហេតុនៃអំពើជួញដូរមនុស្ស ............ ១១
- មាតិកានៃគោលនយោបាយ ............ ១២

**II. ទស្សនាទានអំពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស** ............ ១២

ក. ការកំណត់អត្តសញ្ញាណជនរងគ្រោះ ............ ១២

ខ. មណ្ឌលសំចតរយៈពេលខ្លី ............ ១៣

គ. មណ្ឌលរយៈពេលយូរ ............ ១៣

ឃ. នៅសហគមន៍ ............ ១៣

**III. គំរូនៃកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស** ............ ១៤

- ដំណើរការគ្រប់គ្រងករណីនៃការថែទាំសម្រាប់ជនរងគ្រោះ ............ ១៤
- ការកំណត់អត្តសញ្ញាណជនរងគ្រោះ ............ ១៤
- អន្តរាគមន៍វិបត្តិ ............ ១៤
- ការបញ្ជូន ............ ១៥
- ការទទួល ............ ១៥
- ការរៀបចំផែនការករណី ............ ១៥
- ការប៉ាន់ប្រមាណ ............ ១៥
- ការស្តារ ............ ១៦
- សមាហរណកម្ម ............ ១៦
- ការតាមដាន ............ ១៦
- ការបិទករណី ............ ១៦

បទដ្ឋានអប្បបរមាសម្រាប់កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស

ទី៤ : ប្រកាស លេខ ៨៥៧ ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៩ ស្តីពីបទដ្ឋានអប្បបរមា សម្រាប់កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ........ ២៦

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

ប្រការ ១.– គោលបំណង ........ ២៧

ប្រការ ២.– វិសាលភាព ........ ២៧

ប្រការ ៣.– ស្ថានភាពនៃកិច្ចការពារសិទ្ធិជនរងគ្រោះ ........ ២៧

ប្រការ ៤.– ពន្យល់ពាក្យ ........ ២៧

ប្រការ ៥.– ការបង្គាប់ឱ្យអង្គការមិនមែនរដ្ឋាភិបាលចុះអនុស្សារណៈ ........ ២៨

ជំពូកទី ២

សិទ្ធិ និងបទដ្ឋានអប្បបរមា សម្រាប់កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស

ប្រការ ៦.– សិទ្ធិជនរងគ្រោះ ........ ២៨

១- សិទ្ធិទទួលបានសុវត្ថិភាព និងកិច្ចការពារ ........ ២៨

២- សិទ្ធិទទួលបានអត្តសញ្ញាណបុគ្គល ........ ២៩

៣- សិទ្ធិទទួលបានឯកជនភាពនិងការរក្សាការសម្ងាត់ ........ ២៩

៤- សិទ្ធិទទួលបានសេចក្តីថ្លៃថ្នូរ ........ ៣០

៥- សិទ្ធិទទួលបានព័ត៌មាន ........ ៣០

៦- សិទ្ធិទទួលបានសេវា ........ ៣១

៧- សិទ្ធិទទួលបានយុត្តិធម៌ ........ ៣១

៨- សិទ្ធិទទួលបានប្រក្រតីភាព ........ ៣១

៩- សិទ្ធិចូលរួម ........ ៣១

១០- សិទ្ធិសម្រេចចិត្ត ........ ៣២

១១- សិទ្ធិទទួលបានសេរីភាពបម្លាស់ទី ........ ៣២

ប្រការ ៧.– បទដ្ឋានស្តីពីដំណើរការគ្រប់គ្រងករណី ........ ៣៣

១- ការកំណត់អត្តសញ្ញាណជនរងគ្រោះ ........ ៣៣

២- អន្តរាគមន៍វិបត្តិ ........ ៣៤

៣- ការបញ្ជូន ........ ៣៥

៤- ការទទួល ........ ៣៥

៥- ផែនការករណី ........ ៣៦

៦- ការប៉ាន់ប្រមាណ ........ ៣៦

៧- ការស្តារ ........ ៣៧

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៙*៚

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

លេខ ៨៥២ ស.អ.យ.

*រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៩*

# ប្រកាស

## ស្តីពីការដាក់ឱ្យអនុវត្តគោលនយោបាយ ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៥ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញសេចក្តីណែនាំលេខ ០០៩ ស.អ.យ ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៧ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការងារសមាហរណកម្ម និងតាមដានក្រុមជនរងគ្រោះ ដែលស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល ។

## ស ម្រេ ច

**ប្រការ ១.-**

ត្រូវបានដាក់ឱ្យអនុវត្ត គោលនយោបាយ ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។ គោលនយោបាយ ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស លេខ ០៦២ ស.អ.យ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩ ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣៛៥

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

លេខ ០៦៤ ស.អ.យ.

រាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩

# គោលនយោបាយ

# ស្តីពី

# កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស

## I. គោលការណ៍រួម

អំពើជួញដូរមនុស្សមានន័យថា ជាការជ្រើសរើស ដឹកជញ្ជូន ផ្ទេរ ដឹកតាមផ្លូវទឹក ការទទួលមនុស្ស ដោយប្រើមធ្យោបាយគំរាមកំហែង ប្រើកម្លាំង ទ្រង់ទ្រាយផ្សេងៗ នៃការចាប់បង្ខំ ការចាប់ពង្រត់ ការបន្លំ ការបោកប្រាស់ ការប្រើអំណាច ការដាក់ឱ្យស្ថិតនៅក្នុងសភាពងាយរងគ្រោះ ការផ្តល់ឱ្យ ការទទួល បង់ប្រាក់ ឬផលប្រយោជន៍ដើម្បីទទួលបានការព្រមព្រៀងរបស់មនុស្សម្នាក់ ដើម្បីត្រួតត្រាលើមនុស្សម្នាក់ទៀតក្នុងគោលបំណងកេងប្រវ័ញ្ចន៍ ។

មនុស្សទូទៅអាចត្រូវគេជួញដូរសម្រាប់គោលបំណងជាអាទិ៍ ÷

- ពេស្យាចារ
- ការងារតាមផ្ទះដែលរាប់បញ្ចូលទាំងពលកម្មតាមផ្ទះបែបបង្ខំ ឬកេងប្រវ័ញ្ចន៍
- ពលកម្មកុមារ
- ពលកម្មសំណង់បំណុល
- អាពាហ៍ពិពាហ៍ក្លែងក្លាយ
- សុំកូនខុសច្បាប់
- ទេសចរណ៍ និងការផ្គត់ផ្គង់ផ្លូវភេទ
- អំពើអាសអាភាស
- ការវះកាត់យកសរីរាង្គ
- សុំទាន ពលកម្មគ្រោះថ្នាក់និងកេងប្រវ័ញ្ចន៍
- ការចាត់ធ្វើសកម្មភាពឧក្រិដ្ឋកម្មនានា ។ល។

នៅប្រទេសកម្ពុជា អំពើជួញដូរមនុស្សកើតឡើងនៅក្នុងប្រទេស និងឆ្លងដែន ។ ប្រទេសកម្ពុជាក៏ជាប្រទេសសំចតសម្រាប់ជនដែលត្រូវគេជួញដូរមកពីប្រទេសផ្សេងៗ និងទៅកាន់ប្រទេសផ្សេងៗទៀត ។ អំពើជួញដូរមនុស្សកើតមានឡើងលើបុរស ស្ត្រី និងកុមារនៅប្រទេសកម្ពុជា។ ផលវិបាកដោយសារសង្គ្រាម និងរបបប្រល័យពូជសាសន៍បន្សល់

ខុសច្បាប់ដោយស្ម័គ្រចិត្ត អាចប្រឈមទៅនឹងអំពើជួញដូរ ខណៈពេលដែលលក្ខខណ្ឌដែលបានព្រមព្រៀងគ្នាខុសពីសន្យា ហើយជនដែលធ្វើចំណាកស្រុកនោះអាចរងគ្រោះតាមរយៈការបំពានរាងកាយ ផ្លូវភេទ ផ្លូវចិត្ត និងផ្នែកហិរញ្ញវត្ថុ។ អំពើជួញដូរមនុស្ស ជះឥទ្ធិពលដល់មនុស្សគ្រប់រូបដោយមិនគិតពីភេទ សញ្ជាតិ ដើមកំណើត សាសនា អាយុ សមត្ថភាព និងលើគ្រប់វិស័យ ។ ជនរងគ្រោះដោយអំពើជួញដូរ ត្រូវបានទទួលការយកចិត្តទុកដាក់ក្នុងកិច្ចការពារសុវត្ថិភាព ពីការគំរាមកំហែង អំពើហិង្សា ការរំលោភបំពាន និងផ្តល់តម្រូវការជាមូលដ្ឋានដូចជា ជម្រក អាហារ ការគាំពារផ្នែកវេជ្ជសាស្ត្រ និងចិត្តសាស្ត្រ ផ្តល់កិច្ចការពារខាងផ្លូវច្បាប់ ការរក្សាការសម្ងាត់ និងផ្តល់សំណងផ្លូវច្បាប់ ព្រមទាំងកិច្ចការពារសាក្សីផងដែរ ។

ឯកសារគោលនយោបាយនេះ នឹងណែនាំជាដំបូងឱ្យយល់ដឹងអំពីទស្សនាទាន អំពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្សតាមរូបភាពផ្សេងៗ តាមការយល់ឃើញរបស់អ្នកចូលរួមចំណែកបម្រើការងារលើវិស័យនេះនៅក្នុងប្រទេសកម្ពុជា ( ត្រង់ចំណុច II )។ គំរូសម្រាប់កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ( ត្រង់ចំណុច III) គោលនយោបាយនេះ ក៏បានធ្វើការបង្ហាញអំពីសារៈសំខាន់ នៃគោលនយោបាយស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ( ត្រង់ចំណុច IV) គោលនយោបាយទូទៅស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ( ត្រង់ចំណុច V) ទិសដៅជាក់លាក់សម្រាប់កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ( ត្រង់ចំណុច VI) និងការទទួលខុសត្រូវរបស់ក្រសួងស្ថាប័នមានសមត្ថកិច្ចនៃរាជរដ្ឋាភិបាល ការប្តេជ្ញាចិត្តរបស់មន្ត្រី និងភ្នាក់ងារផ្តល់កិច្ចការពារសិទ្ធិជនរងគ្រោះ ( ត្រង់ចំណុច VII) ។

## II. ទស្សនាទានអំពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស :

ដូចបានលើកឡើងក្នុងគោលដៅរួមរួចមកហើយ គឺមានជនរងគ្រោះដោយអំពើជួញដូរមនុស្សមួយ ឬច្រើនប្រភេទ ក្នុងនោះក៏មានជនរងគ្រោះត្រូវការកិច្ចការពារសិទ្ធិពិសេសសម្រាប់ជីវិតរស់នៅរបស់ខ្លួនផងដែរ។ គោលនយោបាយនេះផ្តោតតែលើសេវាការពារសិទ្ធិជនរងគ្រោះ និងផ្តល់សេវាថែទាំនៅក្នុងមជ្ឈមណ្ឌលរដ្ឋ មណ្ឌលអង្គការមិនមែនរដ្ឋាភិបាល និងនៅក្នុងសហគមន៍[២] ។

### ក. ការកំណត់អត្តសញ្ញាណជនរងគ្រោះ

ជនរងគ្រោះ ឬជនដែលត្រូវគេសង្ស័យថា ជាជនរងគ្រោះអាចត្រូវគេកំណត់អត្តសញ្ញាណភ្លាមនៅកន្លែងណាក៏បាន ។ ហេតុដូចនេះ ការថែទាំជនរងគ្រោះនៅដំណាក់កាលកំណត់អត្តសញ្ញាណជនរងគ្រោះ ក៏អាចកើតឡើងនៅទីតាំងជាច្រើនទៀត ។ ទោះជាយ៉ាងណាក៏ដោយ កន្លែងរួមមួយចំនួនមានដូចជា ប៉ុស្តិ៍ប៉ូលិស ការិយាល័យអន្តោប្រវេសន៍ ឬមណ្ឌល។

ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅប៉ុស្តិ៍ប៉ូលិស ឬការិយាល័យអន្តោប្រវេសន៍ ត្រូវធ្វើឡើងដោយកិច្ចសហការរវាងមន្ត្រីនគរបាល ដែលអាចរួមបញ្ចូលទាំងមន្ត្រីនគរបាលប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន ប៉ូលីសច្រកទ្វារព្រំដែន និងមន្ត្រីសង្គមកិច្ច។

---

២ សេចក្តីណែនាំរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការអនុវត្តសមាហរណកម្ម និងតាមដាន

ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅតាមសហគមន៍ ត្រូវធ្វើឡើងដោយមន្ត្រីសង្គមកិច្ច និង បុគ្គលិកពីអង្គការមិនមែនរដ្ឋាភិបាល ដែលរៀបចំធ្វើការតាមដានជនរងគ្រោះ ដើម្បីពិនិត្យមើលការវិវត្តរបស់ជនរងគ្រោះ ។ ប្រសិនបើជនរងគ្រោះយល់ព្រម មេឃុំ ចៅសង្កាត់ និងគណៈកម្មការស្ត្រី និងកុមារ អាចដើរតួនាទីជួយធ្វើសមាហរណកម្ម និងកាត់បន្ថយការរើសអើងនៅតាមសហគមន៍ ។

## III. គំរូសម្រាប់កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស

### ដំណើរការគ្រប់គ្រងករណីនៃការថែទាំសម្រាប់ជនរងគ្រោះ

ដំណើរការគ្រប់គ្រងករណីចាប់ផ្តើមឡើងនៅពេលដែលជនរងគ្រោះ ឬ ជនដែលអាចជាជនរងគ្រោះ ត្រូវបានកំណត់អត្តសញ្ញាណ ហើយបន្តរហូតដល់ករណីមួយត្រូវបិទ ។ ដំណើរការនេះផ្តល់នូវក្របខណ្ឌមួយសម្រាប់អ្នកផ្តល់សេវា ដែលអាចអនុវត្តសកម្មភាពបង្កើនប្រសិទ្ធភាពជួយជនរងគ្រោះ ។ ដំណាក់កាលក្នុងដំណើរការ គ្រប់គ្រងករណីជានិច្ចកាលមិនមានលក្ខណៈជាលំដាប់លំដោយគ្រប់ករណី តែជំហានជាច្រើនចាំបាច់ត្រូវដំណើរការក្នុងពេលតែមួយក៏មាន។ ដំណាក់កាលក្នុងដំណើរការគ្រប់គ្រងករណីមាន : ការកំណត់អត្តសញ្ញាណជនរងគ្រោះ អន្តរាគមន៍វិបត្តិ ការបញ្ជូន ការទទួល ផែនការករណី ការប៉ាន់ប្រមាណ ការស្តារ សមាហរណកម្ម ការតាមដាន និងបិទករណី។

**ការកំណត់អត្តសញ្ញាណជនរងគ្រោះ** គឺជាដំណើរការកំណត់ថាតើបុគ្គលម្នាក់ ឬ បទពិសោធន៍របស់បុគ្គលមួយក្រុម មានភាពស៊ីសង្វាក់គ្នាទៅនឹងអំពើជួញដូរមនុស្ស ដែលមានចែងក្នុងឯកសារគោលនយោបាយនេះ ស្របទៅនឹងពិធីសារប៉ាឡឺម៉ូ [៣] ។

កត្តាសំខាន់ៗបីដែលចាំបាច់ត្រូវមានសម្រាប់មនុស្សម្នាក់ ក្នុងការកំណត់អត្តសញ្ញាណបានជាជនរងគ្រោះដោយអំពើជួញដូរមនុស្សនោះគឺ ការជ្រើសរើស ការដឹកជញ្ជូន និងការកេងប្រវ័ញ្ច ។ មនុស្សម្នាក់អាចកំណត់អត្តសញ្ញាណបានថាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើជនរងគ្រោះមិនអាចចាកចេញពីកន្លែងដែលកើតមានអំពើជួញដូរមនុស្សដោយងាយស្រួលនិងសេរីទេ ចាំបាច់ត្រូវធ្វើអន្តរាគមន៍ ។ កិច្ចអន្តរាគមន៍គឺជាការទទួលខុសត្រូវរបស់មន្ត្រីនគរបាល ។ អ្នកផ្តល់សេវាដែលបានកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សមិនត្រូវធ្វើការសង្គ្រោះជនរងគ្រោះដោយឯកឯងនោះទេ។ ការធ្វើដូច្នេះ ធ្វើឱ្យជនរងគ្រោះ និងអ្នកផ្តល់សេវាអាចជួបគ្រោះថ្នាក់។

ក្នុងករណីមិនទាន់អាចរកភស្តុតាងផ្សេងៗយកមកគួសបញ្ជាក់មនុស្សម្នាក់ថាជាជនរងគ្រោះនៅឡើយ គួរធ្វើការសន្និដ្ឋានថាជនរូបនោះជាជនរងគ្រោះ។ ជននោះគួរទទួលបានសិទ្ធិ និងសេវាកម្មដូចគ្នាទៅនឹងជនដែលគេកំណត់បានថាជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

**អន្តរាគមន៍វិបត្តិ** គឺសំដៅលើដំណើរការផ្តល់ជំនួយបន្ទាន់រយៈពេលខ្លីជូនជនរងគ្រោះ ដែលទទួលរងនូវព្រឹត្តិការណ៍មួយ ឬច្រើនជាបន្តបន្ទាប់គ្នា ដែលបង្កើតឱ្យមានអតុល្យភាពផ្លូវអារម្មណ៍ ផ្លូវចិត្ត រាងកាយ និង/ឬអាកប្បកិរិយា ដែលបណ្តាលឱ្យជនរងគ្រោះអសមត្ថភាពប្រឈមជាមួយស្ថានភាពបច្ចុប្បន្ន។

---

៣ ពិធីសារប៉ាឡឺម៉ូ គឺជាពិធីសារទប់ស្កាត់ បង្ក្រាប និងដាក់ទោសលើអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ បំពេញបន្ថែម លើសន្ធិសញ្ញាអង្គការសហប្រជាជាតិប្រឆាំងឧក្រិដ្ឋកម្មដែលមានការចាត់តាំងឆ្លងប្រទេស G.A Res. ៥៥/២៦ ។

ការប៉ាន់ប្រមាណត្រូវធ្វើឱ្យបានច្រើនលើកច្រើនសារ ដើម្បីតាមដានការវិវត្តរបស់ជនរងគ្រោះ។ ការប៉ាន់ប្រមាណគួរផ្តល់ឱ្យអ្នកផ្តល់សេវានូវការយល់ដឹង អំពីជោគជ័យនៃកិច្ចអន្តរាគមន៍ ហើយធ្វើឱ្យគេអាចកំណត់នូវអាទិភាពប្រែប្រួលនានា ឬតម្រូវការដែលគួរតែដាក់បញ្ចូលទៅក្នុងផែនការករណី ។ លទ្ធផលដែលបានពីការប៉ាន់ប្រមាណចាំបាច់ត្រូវផ្តល់ព័តិមានជូនជនរងគ្រោះ។

**ការស្តារ** គឺជាដំណើរការធ្វើឱ្យជាសះស្បើយពីភាពដែលធ្លាប់រងនូវការប៉ះទង្គិច ផ្លូវចិត្ត ផ្លូវកាយ ដែលធ្វើឱ្យជនរងគ្រោះគ្មានសមត្ថភាពសម្របខ្លួនជាប្រក្រតីក្នុងមជ្ឈដ្ឋានរបស់ខ្លួន ហើយក៏ជាការបញ្ចូលដំណើរការបង្កើតឡើងនូវសមត្ថភាព ជំនឿទុកចិត្ត ជំនាញ និងអាកប្បកិរិយាចាំបាច់ដើម្បីធ្វើឱ្យជនរងគ្រោះមានសមត្ថភាពប្រក្រតីក្នុងសង្គម ។

ជនរងគ្រោះដោយអំពើជួញដូរមនុស្សម្នាក់ៗមានស្ថានភាពរងគ្រោះដោយឡែកៗពីគ្នា ដូច្នេះការស្តារជនរងគ្រោះក៏មានលក្ខណៈផ្សេងៗពីគ្នាដែរ។ អ្នកផ្តល់សេវាត្រូវធានាអំពីដំណើរការស្តារត្រូវបានតម្រង់ទិសទៅរកតម្រូវការចាំបាច់សមស្របតាមស្ថានភាពរបស់ជនរងគ្រោះម្នាក់ៗ។ សកម្មភាពនៃការស្តាររួមមាន : ការពិគ្រោះយោបល់ ជំនាញបំណិនជីវិត ជំនួយវេជ្ជសាស្ត្រ និងជំនាញវិជ្ជាជីវៈជាដើម។

**សមាហរណកម្ម** គឺជាដំណើរការបញ្ជូនត្រឡប់ជនរងគ្រោះទៅរួមរស់ក្នុងគ្រួសារ និងសហគមន៍ ដោយយោងទៅតាមការសម្រេចចិត្តរបស់ជនរងគ្រោះ ។ ការធ្វើសមាហរណកម្មដោយជោគជ័យជាគោលដៅកំណត់ជាក់លាក់ នៅពេលផ្តល់ជំនួយគាំទ្រដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មាននីតិវិធីប្រកបដោយស្តង់ដា ដែលធានាដល់ការស្តារនីតិសម្បទា និងសមាហរណកម្ម។ នីតិវិធីនេះកំណត់បាននូវតួនាទី និងការទទួលខុសត្រូវច្បាស់លាស់របស់មន្ត្រីសង្គមកិច្ចថ្នាក់ស្រុក ខណ្ឌ ក្រុង ក្នុងដំណើរការសមាហរណកម្ម។ អ្នកផ្តល់សេវាជាតិ និងអន្តរជាតិ ត្រូវធ្វើការពិគ្រោះយោបល់ជាមួយមន្ត្រីសង្គមកិច្ចរាជធានី ខេត្ត ដើម្បីធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

**ការតាមដាន** ជាដំណើរការពិនិត្យលើស្ថានភាពតម្រូវការ និងការវិវត្តរបស់ជនរងគ្រោះនៅពេលបច្ចុប្បន្នបន្ទាប់ពីដំណើរការនៃការធ្វើសមាហរណកម្ម។

ការតាមដានជាជំហានដ៏ចាំបាច់មួយក្នុងដំណើរការគ្រប់គ្រងករណី ព្រោះការធ្វើសមាហរណកម្មទៅគ្រួសារនិងសហគមន៍ អាចប្រឈមនឹងផលប៉ះពាល់ដូចជា : ការប៉ះទង្គិចផ្លូវចិត្តសាជាថ្មី ការរើសអើង កង្វះខាតការទទួលស្គាល់ពីសហគមន៍ ការលំបាកសម្របខ្លួនទៅនឹងការរស់នៅក្នុងសហគមន៍ បន្ទាប់ពីការរស់នៅមណ្ឌលមួយរយៈ។

**ការបិទករណី** ជាដំណើរការបញ្ចប់ករណីរបស់ជនរងគ្រោះ ដែលធ្វើឡើងដោយមានការពិគ្រោះជាមួយជនរងគ្រោះ និងភាគីដែលពាក់ព័ន្ធផ្សេងៗ ហើយក៏បង្ហាញពីការបញ្ចប់ការផ្តល់សេវាផងដែរ។

ការបិទករណីដោយជោគជ័យអាចធ្វើទៅបានតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម [៤]:

- ទំនាក់ទំនងរវាងគ្រួសារ និងជនដែលត្រូវធ្វើសមាហរណកម្ម អាចមានសភាពនឹងនរ និងមាននិរន្តរភាព។

---

៤ សារាចរណ៍ណែនាំ លេខ ០០៩ ស.អ.យ ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៧ ស្តីពីការងារសមាហរណកម្ម និងតាមដានក្រុមជនរងគ្រោះដែលបានស្នាក់នៅក្នុងមណ្ឌលរដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

- គោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៦ ដែលមានការគាំទ្រពីសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

- ប្រកាសលេខ ៦០៦ ស.អ.យ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៦ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌល។

- ប្រកាសលេខ ១៩៨ ស.អ.យ ចុះថ្ងៃទី ១០ ខែ មិនា ឆ្នាំ ២០០៦ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារនៅតាមសហគមន៍។

- គោលការណ៍ណែនាំស្តីពីកិច្ចការពារសិទ្ធិកុមាររងគ្រោះដោយអំពើជួញដូរមនុស្ស រៀបចំដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ CNCC ( អង្គការ យូនីសេហ្វ) ឆ្នាំ ២០០៦។

- សិទ្ធិកុមារទាក់ទងទៅនឹងយុត្តិធម៌កុមារ និងកុមាររងគ្រោះដោយបទល្មើសឧក្រិដ្ឋ : សៀវភៅបណ្តុះបណ្តាលសម្រាប់ចៅក្រម និងព្រះរាជអាជ្ញា រៀបចំដោយអង្គការយូនីសេហ្វ និងរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ឆ្នាំ ២០០៧ ។

ទន្ទឹមនោះមានច្បាប់ និងបទប្បញ្ញត្តិមួយចំនួនដែលកំពុងព្រាងរួមមាន÷

- សេចក្តីព្រាងណែនាំពីវិធីធ្វើការជាមួយកុមាររងគ្រោះ និង សាក្សីក្នុងដំណើរការយុត្តិធម៌កុមារ រៀបចំដោយអង្គការ យូនីសេហ្វ។

- សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីកិច្ចសហការ និង ការសម្របសម្រួលក្នុងដំណើរការយុត្តិធម៌កុមារ។

- សេចក្តីព្រាងច្បាប់យុត្តិធម៌អនីតិជន។

ដើម្បីអនុវត្ត ច្បាប់ អនុស្សរណៈ សេចក្តីប្រកាស សេចក្តីណែនាំ ឱ្យទទួលបាននូវលទ្ធផលល្អ អ្នកផ្តល់សេវាត្រូវប្រកាន់ខ្ជាប់នូវសិទ្ធិរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដូចខាងក្រោម[៥] :

**សិទ្ធិទទួលបានសុវត្ថិភាពនិងកិច្ចការពារ** សំដៅទៅលើសិទ្ធិរបស់ជនរងគ្រោះដោយអំពើជួញដូរ ឬអំពើកេងប្រវ័ញ្ចនីក្នុងការទទួលបានការធានាពីសំណាក់អ្នកដែលធ្វើការជាមួយខ្លួនដែលក្នុងនោះ សន្តិសុខ និងសុខុមាលភាពរបស់ពួកគេត្រូវបានផ្តល់ជាអាទិភាព។

**សិទ្ធិទទួលបានអត្តសញ្ញាណបុគ្គល** សំដៅទៅលើសិទ្ធិរបស់ជនរងគ្រោះគ្រប់រូបដែលត្រូវគេមើលឃើញថាមានចរិតលក្ខណៈ តម្លៃ ឥរិយាបថ និង ជំនឿខុសៗគ្នា ។

**សិទ្ធិទទួលបានឯកជនភាពនិងការរក្សាការសម្ងាត់** គឺសំដៅទៅលើសិទ្ធិរបស់ជនរងគ្រោះ ក្នុងការទទួលបានព័ត៌មានអំពីប្រវត្តិសុខភាព គ្រួសារ សហគមន៍ ឬ ប្រវត្តិអតីតកាលរបស់ពួកគេត្រូវបានការពារ ហើយអាចចែករំលែកបានលុះត្រាមានការសម្រេចផ្ទាល់ពីពួកគេ។

**សិទ្ធិទទួលបានសេចក្តីថ្លៃថ្នូរ** សំដៅទៅលើសិទ្ធិរបស់ជនរងគ្រោះម្នាក់ ក្នុងការទទួលបានការប្រព្រឹត្តចំពោះខ្លួនពីសំណាក់អ្នកដទៃប្រកបដោយការគោរព និងកិត្តិយស ។

---

៥ សិទ្ធិរបស់ជនរងគ្រោះដែលបានកំណត់នេះ មានមូលដ្ឋានចេញពីគោលការណ៍ និងគោលការណ៍ណែនាំស្តីពីសិទ្ធិមនុស្ស និងអំពើជួញដូរមនុស្ស ដែលជាអានុសាសន៍របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមអង្គការសហប្រជាជាតិ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០២ គោលការណ៍ណែនាំខ្ទមឹតសម្រាប់កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅមហាអនុតំបន់ទន្លេមេគង្គ។

### ៣. ទិសដៅទូទៅ

គោលនយោបាយ ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស គឺផ្តល់នូវក្របខណ្ឌមួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សដែលធានាបាននូវការគោរពសិទ្ធិ ផ្តល់នូវសេចក្តីថ្លៃថ្នូរ ផ្តល់នូវកិច្ចការពារសិទ្ធិ និងផលប្រយោជន៍គ្រប់គ្រាន់ធានាការអភិវឌ្ឍន៍ផ្លូវកាយ និងផ្លូវចិត្ត ។ គោលនយោបាយនេះ មានគោលបំណងធានាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស :

- ទទួលបានផលប្រយោជន៍ពីលិខិតូបករណ៍ ច្បាប់ជាតិ និងអន្តរជាតិ ។
- ទទួលបានសិទ្ធិអំណាច និងអាចមានលទ្ធភាពធ្វើ សមាហរណកម្មទៅកាន់គ្រួសារ និងសហគមន៍វិញដោយជោគជ័យជាស្ថាពរ ។
- មានលទ្ធភាពទទួលបាននូវការឧបត្ថម្ភទាំងផ្នែកសម្ភារៈ និងស្មារតី ពិសេសសេវាសុខភាព សេវាអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ។
- ទទួលបាននូវកិច្ចការពារសិទ្ធិយ៉ាងល្អប្រសើរ ឆ្លងផុតពីភាពរងគ្រោះសាជាថ្មី និងការរើសអើង ។

### ៤. ឧបសគ្គ

គ្រប់កម្មវិធីទាំងអស់ និងអ្នកផ្តល់សេវា ដើម្បីជួយជនរងគ្រោះដោយអំពើជួញដូរមនុស្សនឹងជួបបញ្ហាប្រឈមមួយចំនួនដូចជា :

- ការយល់ដឹងអំពីសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅមានកម្រិត ។
- ការយល់ដឹងពីអំពើជួញដូរមនុស្សក្នុងសង្គមនៅមានកម្រិត ។
- កង្វះធនធានមនុស្ស ធនធានសម្ភារៈ ថវិកា សម្រាប់អនុវត្តកម្មវិធីជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។
- ការអនុវត្តន៍ច្បាប់ជាតិ និងអន្តរជាតិដែលកម្ពុជាបានផ្តល់សច្ចាប័នមិនទាន់បានគ្រប់ជ្រុងជ្រោយ ។
- ការងារសម្របសម្រួលការផ្តល់សេវា នៅមានកម្រិតក្នុងចំណោមស្ថាប័នរដ្ឋ ក៏ដូចជាជាមួយអង្គការនានា និងសង្គមស៊ីវិល ដែលធ្វើការពាក់ព័ន្ធជាមួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។
- មិនទាន់មានប្រព័ន្ធរួមនៃការពិនិត្យ តាមដាន និងវាយតម្លៃ ។
- ផលវិបាកមួយចំនួនដែលបណ្តាលមកពីទំនើបភាវូបនីយកម្ម ក៏ដូចជាបញ្ហាបុគ្គលនិយម ការចុះថយនៃតម្លៃ ទំនៀមទម្លាប់ ប្រពៃណី ការថយចុះសាមគ្គីភាពជាដើម ។

ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នឹងជួបបញ្ហាប្រឈមជាក់ស្តែង ដូចខាងក្រោមនេះ :

- កង្វះការគាំទ្រ និងបរិយាកាសជាគ្រួសារល្អ និងកង្វះមណ្ឌលដែលសមស្របសម្រាប់ថែរក្សាជនរងគ្រោះ ។
- ការធ្វើបាបផ្លូវភេទ និងកេងប្រវ័ញ្ចន៍ផ្លូវភេទ ។
- កង្វះលទ្ធភាពទទួលបានសេវាអប់រំ សុខភាព និងការស្តារនីតិសម្បទា ។
- ទទួលព័ត៌មានមិនគ្រប់គ្រាន់អំពីឥទ្ធិពលមិនល្អបណ្តាលមកពីចំណាកស្រុក ។

- បង្កើនលទ្ធភាពដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ទទួលបានសេវាមូលដ្ឋានចាំបាច់នានា ។
- ធ្វើការត្រួតពិនិត្យ តាមដាន និងវាយតម្លៃទៀងទាត់ ដើម្បីធានាឱ្យកម្មវិធីទាំងឡាយដែលតម្រង់ទិសទៅរកជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីបំពេញបាននូវរាល់សេចក្តីត្រូវការរបស់ជនរងគ្រោះ និងធានាឱ្យការអភិវឌ្ឍន៍កម្មវិធីចេះតែបន្តជានិរន្តរ៍និងត្រូវបានបង្កើន ដើម្បីជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

## VI~ ទិសដៅកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស

### ក. ការទទួលជនរងគ្រោះ ដែលបានធ្វើមាតុភូមិនិវត្តន៍ពីក្រៅប្រទេស

ធានាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវបានទទួលតាមរយៈដំណើរការមាតុភូមិនិវត្តន៍ និងនិរទេសដោយគ្មានការរើសអើងលើ ជាតិសាសន៍ សាសនា វណ្ណៈ ពិការភាព ឬភេទ ដោយប្រកាន់ខ្ជាប់នូវសិទ្ធិរបស់ជនរងគ្រោះ និងចាប់ផ្តើមធ្វើផែនការ និងដំណើរការគ្រប់គ្រងករណីរហូតដល់ទទួលបានជោគជ័យក្នុងការបិទករណីជួយជនរងគ្រោះ ។

### ខ. ការបញ្ជូនជនរងគ្រោះត្រឡប់ទៅប្រទេសកំណើត

អ្នកគ្រប់គ្រងករណីជនរងគ្រោះជាជនបរទេស ត្រូវធានាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ទទួលបានសិទ្ធិ និងសេវាដែលចាំបាច់ ដូចជាជនរងគ្រោះដែលមានសញ្ជាតិកម្ពុជាដែរ ហើយមិនមានការរើសអើង ពីពេលចាប់ផ្តើមដំណើរការគ្រប់គ្រងករណីរហូតដល់បិទករណី ។ មុនពេល និងក្នុងពេលធ្វើមាតុភូមិនិវត្តន៍ ត្រូវផ្តល់ព័ត៌មានដែលពាក់ព័ន្ធទាំងអស់ដល់អ្នកផ្តល់សេវានៅប្រទេសទទួល ។

### គ. ការទទួលជនរងគ្រោះពីសមត្ថកិច្ចរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត

អ្នកធ្វើការជាមួយជនរងគ្រោះដោយអំពើជួញដូរមនុស្សទាំងអស់ ត្រូវប្រកាន់ខ្ជាប់នូវសិទ្ធិរបស់ជនរងគ្រោះ ។ មន្ត្រីដែលទទួលភារកិច្ចត្រូវអនុវត្តដំណើរការគ្រប់គ្រងករណីដែលបានកំណត់ក្នុង ( ចំណុចទី III ) ឱ្យទទួលបានជោគជ័យក្នុងការធ្វើសមាហរណកម្ម ។

### ឃ. ការធ្វើសមាហរណកម្មជនរងគ្រោះត្រឡប់ទៅ គ្រួសារ សហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល

ទិសដៅនេះកំណត់ផ្តល់ឱ្យជនរងគ្រោះដោយអំពើជួញដូរមនុស្ស រស់នៅក្នុងជីវភាពសាមញ្ញ " ដូចមុនពេលទទួលរងគ្រោះ " ប្រកបដោយសុខភាពរឹងប៉ឹង និងរីករាយនៅតាមសហគមន៍ដែលគេបានសម្រេចជ្រើសរើស ។ អ្នកផ្តល់សេវាចាំបាច់ ត្រូវធានាដល់ដំណើរការធ្វើសមាហរណកម្ម និងតាមដានដែលបានរៀបចំផែនការត្រៀមលក្ខណៈសម្រាប់ដោះស្រាយតម្រូវការចំពោះជនរងគ្រោះ និង គ្រួសារ ។

## VII~ ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច នៃរាជរដ្ឋាភិបាល និងការប្តេជ្ញាចិត្តរបស់មន្ត្រី និងភ្នាក់ងារផ្តល់កិច្ចការពារសិទ្ធិជនរងគ្រោះ :

### ១- ការទទួលខុសត្រូវរបស់ ក្រសួង ស្ថាប័នមានសមត្ថកិច្ចនៃរាជរដ្ឋាភិបាល :

ក- ពិនិត្យឡើងវិញ ការរៀបចំបង្កើត និង ចងក្រងលិខិតបទដ្ឋានផ្សេងៗទៀតឱ្យស្របទៅតាមអនុសញ្ញាស្តីពីសិទ្ធិមនុស្ស ហើយដែលមានខ្លឹមសារពិសេសពាក់ពន្ធ័ដល់កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរ ។

ង- កៀរគររកថវិកាឱ្យបានគ្រប់គ្រាន់ សម្រាប់ឧបត្ថម្ភមុខសញ្ញាជនរងគ្រោះ និងបែងចែកថវិកាឧបត្ថម្ភដល់កម្មវិធីនានា ឱ្យស្របទៅតាមគោលនយោបាយជាតិ និងបទដ្ឋានអប្បបរមា ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើតួនាទីរបស់ មន្ត្រីរាជការ ក្នុងការពិនិត្យ តាមដាន និងវាយតម្លៃ ។

ច- ជួយអភិវឌ្ឍ និងអនុវត្តដំណោះស្រាយប្រកបដោយនិរន្តរភាព ដោយយកចិត្តទុកដាក់ជាពិសេសទៅលើកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

ឆ- ចូលរួមចំណែកក្នុងការសម្របសម្រួលនានា ជាមួយបណ្តាអង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។

**៣- សហប្រតិបត្តិការរបស់រាជរដ្ឋាភិបាលកម្ពុជាជាមួយប្រទេសជិតខាង និងអង្គការមិនមែនរដ្ឋាភិបាលលើកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស**

**ក. សហប្រតិបត្តិការជាមួយប្រទេសជិតខាង**

១. រៀបចំផែនការសកម្មភាពជាតិស្តីពីអំពើជួញដូរមនុស្ស ដើម្បីអនុវត្តកិច្ចព្រមព្រៀងរាល់ ២ឆ្នាំ ម្តង ។

២. ផ្តួចផ្តើមគំនិត ក្នុងការរៀបចំយុទ្ធសាស្ត្រ គោលការណ៍ បទប្បញ្ញត្តិចាំបាច់នានា ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

៣. លើកឡើងនូវអនុសាសន៍សំដៅឱ្យមានការរីកចម្រើន តទៅទៀតនូវកិច្ចសហប្រតិបត្តិការជួយគ្នាទៅវិញទៅមកក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរបុរស ស្ត្រី និងកុមារ ។

- ពិនិត្យឡើងវិញ និងវាយតម្លៃនូវការអនុវត្តន៍កិច្ចព្រមព្រៀង និងធ្វើរបាយការណ៍ជូនគណៈកម្មការរួមនៃកិច្ចសហប្រតិបត្តិការទ្វេភាគី កម្ពុជា និងវៀតណាម ទ្វេភាគី កម្ពុជា និង ថៃ និងបណ្តាប្រទេសហត្ថលេខីក្នុងកិច្ចប្រជុំប្រចាំរបស់ខ្លួន ដើម្បីដកបទពិសោធន៍សម្រាប់ឆ្នាំបន្តទៀត និងរាយការណ៍ជូនរាជរដ្ឋាភិបាល ។
- ជំរុញការអនុវត្តន៍កិច្ចព្រមព្រៀងនេះឱ្យមានប្រសិទ្ធភាព ដោយសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល និងជំនួយពីអង្គការអន្តរជាតិនានា ដើម្បីបម្រើសកម្មភាពកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។
- ដោះស្រាយការខ្វែងមតិគ្នាលើការបកស្រាយ ឬ ការអនុវត្តកិច្ចព្រមព្រៀងតាមរយៈការចរចា ។ ក្នុងករណីមិនអាចព្រមព្រៀងគ្នាតាមរយៈការចរចា ការខ្វែងមតិនេះ ត្រូវរាយការណ៍ជូនរដ្ឋាភិបាលនៃភាគីហត្ថលេខីដើម្បីដោះស្រាយបញ្ហា ។

**ខ. សហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល ( NGOs )**

១. សហការសម្របសម្រួលជាមួយអង្គការមិនមែនរដ្ឋាភិបាល អង្គការជាតិ អន្តរជាតិ ដើម្បីអនុវត្តគោលនយោបាយ និងបទដ្ឋានជាតិ ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៣✵៣

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

លេខ ៨៥៧ ស.អ.យ.

*រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៩*

# ប្រកាស

## ស្ដីពីបទដ្ឋានអប្បបរមាសម្រាប់កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៥ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញសេចក្ដីណែនាំលេខ ០០៩ ស.អ.យ ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៧ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្ដីពីការងារសមាហរណកម្ម និងតាមដានក្រុមជនរងគ្រោះដែលស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល
- បានឃើញប្រកាសលេខ ៨៥២ ស.អ.យ.ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្ដីពីការដាក់ឱ្យអនុវត្តគោលនយោបាយស្ដីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស

## ស ម្រេ ច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

- អំពើជួញដូរមនុស្ស គឺជាការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការទទួលមនុស្សដោយប្រើមធ្យោបាយគំរាមកំហែង ការប្រើកម្លាំង ឬទម្រង់ទ្រាយផ្សេងៗនៃការចាប់បង្ខំ ការចាប់ពង្រត់ ការបន្លំ ការបោកប្រាស់ ការប្រើអំណាច ឬជាការដាក់ឱ្យស្ថិតនៅក្នុងសភាពងាយរងគ្រោះ ការផ្តល់ឱ្យ ការទទួលបង់ប្រាក់ ឬផលប្រយោជន៍ ដើម្បីទទួលបានការព្រមព្រៀងរបស់មនុស្សម្នាក់ដើម្បីត្រួតត្រាលើមនុស្សម្នាក់ទៀត ក្នុងគោលបំណងកេងប្រវ័ញ្ចន៍

- សិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស គឺជាសិទ្ធិដែលជនរងគ្រោះគ្រប់រូប អាចទទួលបានដោយមិនចាំបាច់ស្វែងរក និងមិនអាចទិញដូរបានឡើយ ។ សិទ្ធិនេះ មានចែងនៅក្នុងសេចក្តីប្រកាសសាកល ស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិនៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៤៨ ។

**ប្រការ ៥.-**

អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិនានា ដែលកំពុងអនុវត្តកម្មវិធី ឬឧបត្ថម្ភគាំទ្រកម្មវិធី និងផ្តល់សេវាកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅគ្រប់ទីកន្លែងនានាក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចុះអនុស្សារណៈ ជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

## ជំពូកទី ២
## សិទ្ធិ និងបទដ្ឋានអប្បបរមា សម្រាប់កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស

**ប្រការ ៦.-**

ស្ថាប័នរដ្ឋ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងសប្បុរសជន ត្រូវគោរពតាមលក្ខខណ្ឌស្តីពីសិទ្ធិជនរងគ្រោះ ដូចខាងក្រោម :

**១- សិទ្ធិទទួលបានសុវត្ថិភាព និងកិច្ចការពារ**

- អ្នកផ្តល់សេវាត្រូវធានាការពារមិនឱ្យអ្នកជួញដូរ និងកេងប្រវ័ញ្ចន៍ ជួបជាមួយជនរងគ្រោះដែលបានសង្គ្រោះ ខណៈពេលដែលជនរងគ្រោះស្ថិតក្រោមការថែទាំរបស់ខ្លួន

- មន្ត្រីពង្រឹងការអនុវត្តន៍ច្បាប់ត្រូវចាត់វិធានការចាំបាច់ ដើម្បីការពារជនរងគ្រោះដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួនដោយឆ្លើយតបទៅនឹងព័ត៌មានឱ្យបានទាន់ពេលវេលា និងសមស្រប

- បរិវេណខាងក្រៅទីកន្លែងរបស់អង្គការ ដែលធ្វើការជាមួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវចាត់វិធានការសមស្រប ដើម្បីធានាឱ្យជនរងគ្រោះមានសុវត្ថិភាព និងសន្តិសុខល្អ ហើយអ្នកក្រៅមិនអាចចេញចូលបានដោយគ្មានការអនុញ្ញាត

- បរិវេណខាងក្នុងរបស់អង្គការដែលធ្វើការជាមួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវចាត់វិធានការសមស្រប ដើម្បីធានារក្សាបាននូវបរិដ្ឋានកម្រិតខ្ពស់ និងធានាសុវត្ថិភាព សុខភាពជនរងគ្រោះដែលរស់នៅក្នុងបរិវេណនោះ

- អង្គការដែលផ្តល់សេវា ត្រូវរៀបចំបុគ្គលិកឱ្យបានត្រឹមត្រូវ ដើម្បីផ្តល់សេវាដែលសមស្របតាមគោលការណ៍យេនឌ័រ ដល់ជនរងគ្រោះ

- ត្រូវមានការយល់ឱ្យបានច្បាស់លាស់ រវាងបុគ្គលិកដែលធ្វើការលើករណីជនរងគ្រោះ និងអ្នកផ្តល់សេវាផ្សេងទៀត អំពីព័ត៌មានដែលសមស្របនិងចាំបាច់ ដើម្បីធ្វើការផ្លាស់ប្តូរព័ត៌មានគ្នាសម្រាប់ការផ្តល់សេវា

- ព័ត៌មានទាក់ទងនឹងផ្នែកវេជ្ជសាស្ត្រ ផ្នែកច្បាប់ និងព័ត៌មានផ្សេងទៀតដែលទាក់ទងនឹងករណីព្រមទាំងសំណុំឯកសាររបស់ជនរងគ្រោះ ត្រូវរក្សាទុកនៅក្នុងកន្លែងមួយដែលមានសុវត្ថិភាព និងសន្តិសុខ

- មានតែមន្ត្រី/បុគ្គលិកដែលទទួលបានការអនុញ្ញាត ហើយដែលត្រូវការព័ត៌មាន ដើម្បីអនុវត្តតួនាទី ភារកិច្ចក្នុងការជួយគាំទ្រដល់ជនរងគ្រោះប៉ុណ្ណោះ ដែលអាចមើលសំណុំឯកសាររបស់ជនរងគ្រោះបាន

- អត្តសញ្ញាណរបស់ជនរងគ្រោះ ត្រូវបានការពារពីការចុះផ្សាយដោយប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដូចមានចែងនៅក្នុងមាត្រា ៤៩ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

**៤- សិទ្ធិទទួលបានសេចក្តីថ្លៃថ្នូរ**

- រាល់ការប្រព្រឹត្តទៅលើជនរងគ្រោះ ក្នុងដំណើរការផ្តល់ជំនួយឧបត្ថម្ភតាំងពីដើមរហូតដល់ចប់ត្រូវតែមានការគោរព និងទទួលស្គាល់ថា ជាបុគ្គលដែលបានឆ្លងកាត់នូវកាលៈទេសៈដ៏លំបាកមួយ ឬ កាលៈទេសៈលំបាកបន្តបន្ទាប់ជាច្រើន

- ទង្វើរើសអើង និង/ឬមាក់ងាយណាមួយចំពោះភេទ អាយុ ជាតិសាសន៍ ដើមកំណើត សាសនា សញ្ជាតិ ជម្រើសទំនោរចិត្តផ្លូវភេទ ពិការភាព ឬ បទពិសោធន៍ពីអតីតកាលទៅលើជនរងគ្រោះត្រូវបានហាមឃាត់ដាច់ខាត ។

**៥- សិទ្ធិទទួលបានព័ត៌មាន**

- ត្រូវផ្តល់ព័ត៌មានដល់ជនរងគ្រោះទាំងអស់ឱ្យបានដឹងអំពីសិទ្ធិរបស់ជនរងគ្រោះ នៅក្នុងដំណើរការផ្តល់ជំនួយដល់ជនរងគ្រោះ

- អ្នកដែលធ្វើការ និងប្រាស្រ័យទាក់ទងជាមួយជនរងគ្រោះ ត្រូវពន្យល់ប្រាប់ពីតួនាទី ភារកិច្ចរបស់ខ្លួនដល់ជនរងគ្រោះ

- ត្រូវពន្យល់ប្រាប់ជនរងគ្រោះ ពីសកម្មភាពនានាដែលជនរងគ្រោះចូលរួម ឬ ត្រូវបានអញ្ជើញចូលរួមផងដែរ

- ជនរងគ្រោះមានសិទ្ធិទទួល និងប្រើប្រាស់ព័ត៌មាន និងទទួលបានការពន្យល់អំពីឯកសារទាក់ទងនឹងផ្នែកសុខភាព វេជ្ជសាស្ត្រ ច្បាប់ និងគ្រប់ករណីដែលពាក់ព័ន្ធនឹងជនរងគ្រោះ

- ត្រូវផ្តល់អ្នកបកប្រែឱ្យជនរងគ្រោះដែលមិនចេះនិយាយ និង/ឬអានភាសាខ្មែរ ដើម្បីពួកគេអាចយល់អំពីព័ត៌មានជាលាយលក្ខណ៍អក្សរ និងនិយាយផ្ទាល់មាត់ ។ ក្នុងករណីជនរងគ្រោះជាជនពិការ គ ថ្លង់ ត្រូវរកអ្នកចេះប្រើភាសាសញ្ញា ដើម្បីធ្វើការជាមួយជនរងគ្រោះ

- សម្រាប់កុមាររងគ្រោះ អ្នកផ្តល់សេវាត្រូវធ្វើការសម្រេចចិត្តទាក់ទិនទៅនឹងចំនួនព័ត៌មានដែលត្រូវផ្តល់ឱ្យ និងលក្ខណៈសមស្របដែលគិតដល់ឧត្តមប្រយោជន៍របស់កុមារ ដោយយោងទៅតាមអាយុ និងកម្រិតរងគ្រោះដែលកុមារបានទទួល ។

- ត្រូវជូនដំណឹងឱ្យជនរងគ្រោះ បានដឹងជាមុនគ្រប់ទិដ្ឋភាព និងបញ្ហាទាំងអស់ដែលទាក់ទងទៅនឹងករណីរបស់ជនរងគ្រោះ ក្នុងគោលបំណងឱ្យជនរងគ្រោះមានលទ្ធភាពយកបញ្ហាទាំងឡាយទៅពិចារណាក្នុងដំណាក់កាលផ្សេងៗ នៃដំណើរការជួយជនរងគ្រោះ

- ត្រូវពិគ្រោះយោបល់ជាមួយជនរងគ្រោះឱ្យបានច្បាស់លាស់ក្នុងការកំណត់លក្ខណៈវិនិច្ឆ័យ សម្រាប់ការចូលរួមរបស់ពួកគេ ជៀសវាងការគាបសង្កត់ គំរាមកំហែង ឬទទួលរងការជះឥទ្ធិពលមិនល្អពីអ្នកដទៃ

- ជនរងគ្រោះដែលជាអនីតិជន មានសិទ្ធិចូលរួមនៅក្នុងដំណើរការធ្វើផែនការសម្រាប់អនាគត និងសម្តែងទស្សនៈផ្ទាល់ខ្លួនដែលសមស្រប ហើយអាចសម្រេចបានជោគជ័យសម្រាប់អនាគត ព្រមទាំងស្របតាមអនុសញ្ញាអន្តរជាតិ និងកិច្ចព្រមព្រៀងផ្សេងៗ ដែលរាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខា និងផ្តល់សច្ចាប័ន។

**១០- សិទ្ធិសម្រេចចិត្ត**

- ត្រូវផ្តល់ការលើកទឹកចិត្ត និងគាំទ្រដល់ជនរងគ្រោះដើម្បីធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវ

- ជនរងគ្រោះ ត្រូវមានសិទ្ធិទទួលបាននូវរយៈពេលគិតគូរពិចារណាសមស្រប មុនពេលធ្វើការសម្រេចចិត្ត និងមិនត្រូវមានជនណាម្នាក់ស្នើសុំ ឬបង្ខំឱ្យធ្វើការសម្រេចចិត្តដោយប្រញាប់ប្រញាល់ឡើយ

- ក្នុងករណីការសម្រេចចិត្តរបស់ជនរងគ្រោះ មិនអាចអនុវត្តទៅបាន អ្នកផ្តល់សេវា ឬអ្នកពិគ្រោះយោបល់ត្រូវជួយជនរងគ្រោះក្នុងការកំណត់រកដំណោះស្រាយផ្សេងជំនួសវិញឱ្យបានសមស្រប

- សម្រាប់ជនរងគ្រោះជាមនុស្សពេញវ័យ ការសម្រេចចិត្តអាចធ្វើជំនួសបានលុះត្រាតែជនរងគ្រោះគ្មានលទ្ធភាពធ្វើការសម្រេចចិត្តដោយខ្លួនឯង ដោយសារការរងគ្រោះផ្នែករាងកាយ និង/ឬស្មារតី ឬ អសមត្ថភាពផ្នែកប្រាជ្ញា។ ក្នុងករណីចាំបាច់ត្រូវពិគ្រោះយោបល់ជាមួយក្រុមគ្រួសារ សាច់ញាតិ អំពីការសម្រេចចិត្តរបស់ជនរងគ្រោះ

- ជនរងគ្រោះជាកុមារ ត្រូវមានសិទ្ធិចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត ហើយត្រូវអនុវត្តសេចក្តីសម្រេចចិត្តរបស់កុមារទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន ដោយមិនធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសុខុមាលភាពរបស់កុមារ

- ក្នុងករណីដែលមិនអាចធ្វើការពិគ្រោះយោបល់ជាមួយកុមាររងគ្រោះបាន អ្នកផ្តល់សេវា ឬអ្នកពិគ្រោះយោបល់ ត្រូវពន្យល់បញ្ជាក់ពីមូលហេតុនៃការធ្វើសេចក្តីសម្រេចចិត្តទាំងនោះ និងអំពីសារប្រយោជន៍អ្វីខ្លះ ដែលកុមាររងគ្រោះបានទទួល ។

**១១- សិទ្ធិទទួលបានសេរីភាពបម្លាស់ទី**

- ជនរងគ្រោះជាជនបរទេសគ្រប់រូប មានសិទ្ធិទទួលបានការធ្វើមាតុភូមិនិវត្តន៍ដោយឆាប់រហ័ស និងមានលក្ខណៈមនុស្សធម៌ ទៅកាន់ប្រទេសកំណើតរបស់ខ្លួនវិញ

- ស្ថិតនៅក្នុងប្រទេសកំណើត ជនរងគ្រោះមានសិទ្ធិទទួលបានការធ្វើសមាហរណកម្មទៅក្នុងសហគមន៍ដែលខ្លួនជ្រើសរើស និងធ្វើការបម្លាស់ទីពីសហគមន៍មួយទៅសហគមន៍មួយទៀត តាមបំណងប្រាថ្នារបស់ខ្លួនផ្ទាល់

- ជនរងគ្រោះជាមនុស្សពេញវ័យដែលគ្មានទោស មានសិទ្ធិចាកចេញពីស្ថាប័នដែលមានសមត្ថកិច្ចអនុវត្តន៍ច្បាប់ ឬអ្នកផ្តល់សេវា ក្រោយពេលបានផ្តល់ព័ត៌មានដល់អាជ្ញាធរ ឬស្ថាប័នមានសមត្ថកិច្ចរួច ។ គ្មានជនណាម្នាក់មានសិទ្ធិ ឃាត់ខ្លួនជនរងគ្រោះទុកផ្ទុយនឹងឆន្ទៈរបស់ពួកគេឡើយ

ធ្វើឱ្យបានរហ័សនូវដំណើរការកំណត់អត្តសញ្ញាណជនរងគ្រោះ និងចាត់អាទិភាពលើការកំណត់អាយុ ដើម្បីស្វែងរកសេវាសម្រាប់ ផ្តល់ជូនជនរងគ្រោះឱ្យមាន លក្ខណៈសមស្រប

- អ្នកសម្ភាសន៍ត្រូវប្រើវិធីសាស្ត្រផ្តោតសំខាន់ទៅលើកិច្ចការការពារប្រយោជន៍ជនរងគ្រោះ ដោយគិតគូរដល់ផលប៉ះពាល់ផ្លូវចិត្ត ដែលជនរងគ្រោះធ្លាប់បានទទួលរងគ្រោះ និងជៀសវាងការប៉ះទង្គិចផ្លូវចិត្តសាជាថ្មីម្តងទៀតដល់ជនរងគ្រោះ

- កិច្ចសម្ភាសន៍កំណត់អត្តសញ្ញាណជនរងគ្រោះ មិនត្រូវចាប់ផ្តើមធ្វើនៅពេលសេវាស្តារ ផ្នែកវេជ្ជសាស្ត្រ និងផ្នែកចិត្តសាស្ត្រសំខាន់ៗមិនទាន់បានផ្តល់ឱ្យជនរងគ្រោះនោះឡើយ

- កិច្ចសម្ភាសន៍កំណត់អត្តសញ្ញាណជនរងគ្រោះ ត្រូវខិតខំសម្ភាសន៍ក្នុងរយៈពេលខ្លី គឺត្រូវសួរតែព័ត៌មានសំខាន់ៗដូចជា ឈ្មោះ អាយុ អាសយដ្ឋាន ឬ ទីកន្លែងកំណើត ការគំរាមកំហែងចំពោះសុវត្ថិភាព និងសេចក្តីត្រូវការបន្ទាន់ៗរបស់ជនរងគ្រោះ

- ត្រូវមានមនុស្សម្នាក់ជាជំនួយការដល់ជនរងគ្រោះ ក្នុងដំណើរការកំណត់អត្តសញ្ញាណ តាំងពីដើមរហូតដល់បញ្ចប់ ។

**២- អន្តរាគមន៍វិបត្តិ**

- អ្នកផ្តល់សេវាត្រូវស្វែងយល់ឱ្យបានច្បាស់ពីលក្ខណៈសម្បត្តិ និងបញ្ហាទូទៅរបស់ជនរងគ្រោះ ពិសេសដំណាក់កាលធ្លាក់ខ្លួនមានវិបត្តិ ដើម្បីស្វែងរកចំណុចជាក់លាក់ដែលជនរងគ្រោះបានទទួលរងនូវវិបត្តិទាំងនោះ និងត្រូវដឹងច្បាស់លាស់ថា ជនរងគ្រោះត្រូវការអន្តរាគមន៍បែបណាដែលសមស្របសម្រាប់ប្រភេទជនរងគ្រោះនីមួយៗ

- តម្រូវការអន្តរាគមន៍វិបត្តិ ត្រូវកំណត់ដោយផ្អែកលើសេចក្តីត្រូវការចាំបាច់សំខាន់ៗរបស់ជនរងគ្រោះ

- នៅមុនពេលអនុវត្តអន្តរាគមន៍វិបត្តិ ការប៉ាន់ប្រមាណគ្រោះថ្នាក់ដែលមានចែងក្នុងចំណុចទី ៦នៃដំណើរការគ្រប់គ្រងករណីត្រូវអនុវត្តឱ្យបានល្អ ដើម្បីកាត់បន្ថយភាពគ្រោះថ្នាក់ដល់ជនរងគ្រោះ និងឧបសគ្គចំពោះអ្នកផ្តល់សេវា

- ក្នុងករណីអ្នកផ្តល់សេវាមានលទ្ធភាពអាចទាក់ទងជនរងគ្រោះបានមុនពេលអនុវត្តអន្តរាគមន៍វិបត្តិ ត្រូវទាក់ទងដើម្បីត្រៀមលក្ខណៈអនុវត្តជំហានបន្ទាប់ឱ្យមានប្រសិទ្ធភាពខ្ពស់

- នៅមុនពេលធ្វើអន្តរាគមន៍ចំពោះជនរងគ្រោះ ត្រូវរៀបចំសេវានានា និងសម្ភារៈផ្គត់ផ្គង់ផ្សេងៗ ដែលជនរងគ្រោះត្រូវការមុន និងក្រោយពេលអន្តរាគមន៍វិបត្តិ

- អន្តរាគមន៍វិបត្តិ ត្រូវធ្វើឡើងក្នុងលក្ខណៈមួយដែលមានសុវត្ថិភាព និងសន្តិសុខ ដើម្បីកាត់បន្ថយការប៉ះទង្គិចផ្លូវកាយ និងផ្លូវចិត្តរបស់ជនរងគ្រោះ និងអ្នកដទៃទៀតដែលពាក់ព័ន្ធ

- ក្នុងអំឡុងពេលអន្តរាគមន៍វិបត្តិ ត្រូវបំបែកជនរងគ្រោះចេញពីជនសង្ស័យ ហើយត្រូវមានវិធានការរារាំងមិនឱ្យមានការប្រាស្រ័យទាក់ទងរវាងជនរងគ្រោះ និងជនសង្ស័យ

- មនុស្សដែលប្រាស្រ័យទាក់ទងជាមួយជនរងគ្រោះក្នុងពេល និងក្រោយពេលអន្តរាគមន៍វិបត្តិ ត្រូវធានាការពារទ្រព្យសម្បត្តិរបស់ជនរងគ្រោះមិនឱ្យបាត់បង់

**៥- ផែនការករណី**

- ការធ្វើផែនការករណី និងគ្រប់សកម្មភាពទាំងអស់ ត្រូវផ្ដោតសំខាន់ទៅលើសេចក្ដីត្រូវការរបស់ជនរងគ្រោះ ហើយចាំបាច់ត្រូវបានពិគ្រោះយោបល់ និងផ្ដល់ព័ត៌មានជាប្រចាំ អំពីសកម្មភាពនានាដែលមានក្នុងផែនការករណី ជាមួយជនរងគ្រោះ

- នៅពេលដែលជនរងគ្រោះត្រូវបានកំណត់អត្តសញ្ញាណ ការធ្វើផែនការករណីត្រូវធ្វើឡើងឱ្យបានឆាប់បំផុត និងត្រូវបានការចូលរួមយ៉ាងសកម្មពីជនរងគ្រោះ

- ត្រូវពិនិត្យផែនការករណីឱ្យបានញឹកញាប់ ដើម្បីបត់បែនឱ្យទាន់សភាពការណ៍ជាក់ស្ដែង

- ផែនការករណីត្រូវមានភាពជាក់លាក់អាចព្យាករណ៍បានអំពីលទ្ធផលជោគជ័យខ្ពស់ ក្នុងនោះត្រូវមានការបញ្ជាក់អំពីការទទួលខុសត្រូវរបស់ភាគីអ្នកផ្ដល់សេវា និងរយៈពេលកំណត់ សម្រាប់សកម្មភាពក្នុងផែនការករណី

- ដំណើរការនៃការអនុវត្តន៍ផែនការករណី ត្រូវមានការកត់ត្រាច្បាស់លាស់និងរក្សាទុកជាការសម្ងាត់

- ត្រូវផ្ដល់ផែនការករណីដល់ជនរងគ្រោះ ក្នុងករណីសាមីខ្លួនស្នើសុំ

- ក្នុងករណីដែលសមស្រប និងមានការយល់ព្រមពីជនរងគ្រោះ ផែនការករណីត្រូវធ្វើឡើងជាមួយអ្នកដែលមានតួនាទី ភារកិច្ចពាក់ព័ន្ធទាំងអស់។

**៦- ការប៉ាន់ប្រមាណ**

- នៅពេលដែលមនុស្សម្នាក់ត្រូវបានកំណត់អត្តសញ្ញាណថាជាជនរងគ្រោះ ការប៉ាន់ប្រមាណពីសុខភាពផ្លូវកាយ និងផ្លូវចិត្ត ត្រូវចាត់ទុកជាអាទិភាព

- អ្នកផ្ដល់សេវាត្រូវទទួលស្គាល់ថា ការប៉ាន់ប្រមាណគឺជាដំណើរការបន្តបន្ទាប់មួយ ដែលគ្របដណ្ដប់លើទិដ្ឋភាពជាច្រើនរួមមាន : ការវាយតម្លៃ និងការសម្ភាសន៍ដំបានដំបូង ការវាយតម្លៃ និងការសម្ភាសន៍បន្តលម្អិត ការវាយតម្លៃអំពីសុខភាពផ្លូវកាយ និងផ្លូវចិត្ត ការវាយតម្លៃអំពីភាពប្រឈមនឹងគ្រោះថ្នាក់ អំពីការពាក់ព័ន្ធនឹងទិដ្ឋភាពច្បាប់សង្គម អំពីមណ្ឌល អំពីមន្ត្រី បុគ្គលិក អំពីសហគមន៍ និងគ្រួសារ អំពីមុខជំនាញ និងលទ្ធភាព ព្រមទាំងវាយតម្លៃ អំពីកម្រិតជីវភាពរបស់ជនរងគ្រោះ

- អ្នកផ្ដល់សេវាត្រូវយល់ដឹងអំពីរបៀបវាយតម្លៃ និងរបៀបសម្ភាសន៍ដែលត្រូវអនុវត្ត ព្រមទាំងពេលវេលា និងវិធីដែលសមស្របបំផុត ដើម្បីធ្វើការវាយតម្លៃ

- ការប៉ាន់ប្រមាណអំពីគ្រោះថ្នាក់របស់ជនរងគ្រោះ ដែលត្រូវរស់នៅក្នុងគ្រួសារ និងសហគមន៍ ត្រូវធ្វើឡើងភ្លាមឱ្យបានរហ័ស ដើម្បីកំណត់លទ្ធភាពនៃការធ្វើសមាហរណកម្មទៅកាន់សហគមន៍ទទួលបានលទ្ធផលល្អប្រសើរ

- អ្នកផ្ដល់សេវាត្រូវរៀបចំធ្វើការប៉ាន់ប្រមាណ អំពីគុណភាពសេវាដែលខ្លួនបានផ្ដល់មួយឆ្នាំម្ដងយ៉ាងតិច

- មុនពេលធ្វើការប៉ាន់ប្រមាណ អ្នកផ្ដល់សេវាត្រូវស្វែងយល់ពីព័ត៌មាននានា ដែលទាក់ទិនទៅនឹងករណីនីមួយៗជៀសវាងសំណួរគ្មានប្រយោជន៍ ខាតពេលវេលា ហើយដែលអាចធ្វើឱ្យជនរងគ្រោះទទួលរងការប៉ះទង្គិចផ្លូវចិត្តសាជាថ្មី

- សមាហរណកម្មត្រូវចាប់ផ្តើមធ្វើឡើង នៅពេលដែលធ្វើការប៉ាន់ប្រមាណត្រឹមត្រូវ អំពីលក្ខណៈដោយឡែករបស់ជនរងគ្រោះម្នាក់ៗ និងទីកន្លែងដែលជនរងគ្រោះត្រូវធ្វើសមាហរណកម្មចប់សព្វគ្រប់

- សមាហរណកម្ម ត្រូវចាប់ផ្តើមឡើងជាលក្ខណៈសាកល្បង ហើយអ្នកផ្តល់សេវាត្រូវបន្តវាយតម្លៃនិរន្តរភាពសុវត្ថិភាព កន្លែងរស់នៅ និងសុខុមាលភាពរបស់ជនរងគ្រោះឱ្យបានជាប្រចាំ

- អ្នកផ្តល់សេវាត្រូវដឹងថា សមាហរណកម្មអាចបង្កជាស្ថានការណ៍វិបត្តិមួយបាន ហើយត្រូវតែធ្វើការពិនិត្យ តាមដានការធ្វើសមាហរណកម្មនោះ ដើម្បីកំណត់ថាតើជនរងគ្រោះត្រូវការសេវា និងការគាំទ្របន្ថែមទៀត ឬយ៉ាងណា

- ក្នុងករណីចាំបាច់ ជាពិសេសជនរងគ្រោះជាកុមារ ត្រូវផ្តល់ជំនួយដល់គ្រួសាររបស់ជនរងគ្រោះ ក្នុងទម្រង់ជាការពិគ្រោះបញ្ហា ការបណ្តុះបណ្តាលអំពីការចិញ្ចឹមថែទាំកូន និងគម្រោងទ្រទ្រង់ជីវភាព នៅក្រោយការវាយតម្លៃអំពីភាពប្រឈម និងតម្រូវការជាមូលដ្ឋាន

- ក្នុងករណីជនរងគ្រោះជាអនីតិជន អ្នកផ្តល់សេវាត្រូវចាត់វិធានការនានា ដើម្បីធានាឱ្យជនរងគ្រោះបានបន្តការសិក្សាតាមកម្រិតរបស់ខ្លួន ។

## ៩- ការតាមដាន

- ត្រូវរៀបចំផែនការតាមដានករណីដែលមានលក្ខណៈរស់រវើក បត់បែន ទាន់សភាពការណ៍ ហើយធ្វើបច្ចុប្បន្នភាពជាទៀងទាត់ និងត្រូវផ្តល់អាទិភាពចម្បងទៅលើសេចក្តីត្រូវការ និងដោះស្រាយបញ្ហាប្រឈមរបស់ជនរងគ្រោះ

- ត្រូវកំណត់ចំនួនលើក ដែលត្រូវចុះពិនិត្យតាមដានដោយផ្អែកលើការពិភាក្សាជាមួយជនរងគ្រោះ និងអ្នកផ្តល់សេវា ។ ចំនួននេះអាចនឹងមានការកែប្រែ ដោយផ្អែកលើតម្រូវការចាំបាច់របស់ជនរងគ្រោះ

- ក្នុងផ្នែកនៃដំណើរការតាមដាន អ្នកតាមដានត្រូវផ្សារភ្ជាប់ជនរងគ្រោះទៅនឹងសេវាដែលអាចរកបាននៅក្នុងសហគមន៍ ឬភូមិកំណើតរបស់ជនរងគ្រោះ

- ត្រូវជូនដំណឹងឱ្យជនរងគ្រោះបានដឹងជាមុនអំពីពេលវេលាជាក់លាក់ នៃការចុះតាមដាន លើកលែងតែក្នុងករណីពិសេស ដែលអ្នកតាមដានចង់ពិនិត្យស្ថានភាពជាក់ស្តែងដល់ទីកន្លែង ក្រោយពេលធ្វើសមាហរណកម្ម

- ការចុះតាមដានត្រូវអនុវត្តដោយប្រុងប្រយ័ត្ន ស្របទៅតាមសំណើ និងស្ថានភាពរបស់ជនរងគ្រោះ ។

## ១០- ការបិទករណី

- នៅមុនពេលបិទករណី បញ្ហាចម្បង អ្នកផ្តល់សេវាត្រូវធានាអំពីសុខភាពរបស់ជនរងគ្រោះពិតជាល្អប្រសើរ ។ ជនរងគ្រោះមានស្ថិរភាពខាងផ្លូវចិត្ត និងផ្នែកហិរញ្ញវត្ថុ មានអារម្មណ៍កក់ក្តៅទៅនឹងជីវិតរស់នៅក្នុងសហគមន៍ និងគ្រួសារមានលំនឹងក្នុងការដោះស្រាយជីវភាពប្រចាំថ្ងៃរបស់ខ្លួន

- អ្នកផ្តល់សេវាត្រូវពិគ្រោះយោបល់ជាមួយជនរងគ្រោះដើម្បីសម្រេចបិទករណី

- ក្នុងករណីដែលជនរងគ្រោះមិនអាចទំនាក់ទំនងបាន អ្នកផ្តល់សេវាត្រូវរកគ្រប់វិធី ស្វែងរកជនរងគ្រោះដូចជា ទាក់ទងជាមួយក្រុមគ្រួសារ និងអ្នកផ្តល់សេវាផ្សេងៗទៀត នៅមុនពេលធ្វើការបិទករណីរបស់ជនរងគ្រោះម្នាក់ៗ

- អ្នកផ្តល់សេវាត្រូវទទួលស្គាល់ថា បញ្ហាផ្ទាល់ខ្លួនអាចនឹងប៉ះពាល់ដល់ការងាររបស់ជនរងគ្រោះ ជាពិសេស បញ្ហាដែលប្រហាក់ប្រហែលទៅនឹងបញ្ហារបស់ជនរងគ្រោះ។ បើចាំបាច់ អ្នកផ្តល់សេវាអាចពិភាក្សាជាមួយគ្រួសារ មិត្តភ័ក្រ្ត និង/ឬសហការីដែលខ្លួនទុកចិត្ត ដែលមានវិជ្ជាជីវៈប្រហាក់ប្រហែលដើម្បី រកជំនួយមុនពេលដែលបញ្ហានោះធ្វើឱ្យដំណើរការ ផ្តល់សេវាមិនមានប្រសិទ្ធភាព។ ក្នុងករណីបញ្ហារបស់ខ្លួនមិនអាចដោះស្រាយបាន ចាំបាច់ត្រូវផ្ទេរករណីដែលកំពុងដំណើរការ ឱ្យអ្នកផ្តល់សេវាម្នាក់ទៀតអនុវត្តបន្ត

- អ្នកផ្តល់សេវាត្រូវរៀនសូត្ររំឭកឡើងវិញទាំងទ្រឹស្តី និងសកម្មភាព ហើយត្រូវពង្រឹងបន្ថែមជាបន្ត បន្ទាប់នូវមុខជំនាញដែលទាក់ទងនឹងការងារផ្តល់សេវា ដើម្បីបង្កើនប្រសិទ្ធភាពគុណភាពក្នុងការផ្តល់សេវាឱ្យកាន់តែ ប្រសើរឡើង ។

**២- អ្នកគ្រប់គ្រងអ្នកផ្តល់សេវា**

- អ្នកគ្រប់គ្រងត្រូវផ្តល់ព័ត៌មានដល់អ្នកផ្តល់សេវា អំពីការងារស្មុគស្មាញតានតឹង នឿយហត់ផ្លូវកាយ ផ្លូវចិត្ត និងការប៉ះទង្គិចផ្លូវចិត្តដែលជួបប្រទះក្នុងពេលអនុវត្តការងារផ្តល់សេវាដល់ជនរងគ្រោះ

- អ្នកគ្រប់គ្រងត្រូវផ្តល់ឱកាសក្នុងការកាត់បន្ថយភាពតានតឹង ដល់អ្នកផ្តល់សេវាទាំងឡាយដែលស្ថិតក្រោម ការគ្រប់គ្រងរបស់ខ្លួន

- អ្នកគ្រប់គ្រងត្រូវពិនិត្យមើលអាកប្បកិរិយា និងពិនិត្យសញ្ញានឿយហត់ផ្លូវកាយ ផ្លូវចិត្ត ឬការប៉ះទង្គិច ផ្លូវចិត្តដែលអាចឆ្លងពីអ្នកដទៃ និង/ឬជនរងគ្រោះ ក្នុងករណីបែបនេះអ្នកគ្រប់គ្រងត្រូវពិភាក្សាជាមួយអ្នកផ្តល់សេវាដើម្បី ដោះស្រាយឱ្យបានសមស្រប

- ត្រូវមានគម្រោងថវិកាសម្រាប់សកម្មភាពកាត់បន្ថយភាពតានតឹង នឿយហត់ដល់អ្នកផ្តល់សេវាដើម្បី បង្កើនប្រសិទ្ធភាពការងារផ្តល់សេវា ។

## ជំពូកទី ៣
## ការគ្រប់គ្រងករណី

**ប្រការ ៩.-**

មជ្ឈមណ្ឌលរដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល ដែលចុះកិច្ចព្រមព្រៀងជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តដំណាក់កាលនៃដំណើរការធ្វើសមាហរណកម្ម និងតាមដាន ដែលមានចែងក្នុងសារាចរ ណែនាំ លេខ ០០៩ ស.អ.យ ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៧ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការងារសមាហរណកម្ម និងតាមដានក្រុមជនរងគ្រោះដែលបានស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ និងអង្គការ មិនមែនរដ្ឋាភិបាល ដូចខាងក្រោម :

១- ដំណាក់កាលមុនពេលសមាហរណកម្ម

២- ដំណាក់កាលធ្វើសមាហរណកម្ម

៣- ការតាមដានប្រភេទ ១

៤- ការតាមដានប្រភេទ ២

៤- ការប៉ាន់ប្រមាណស្ថានភាពគ្រួសារ ផ្ទះសម្បែងរបស់ជនរងគ្រោះ ដើម្បីបញ្ជាក់ថាមានការរំលោភបំពាន ឬការមិនយកចិត្តទុកដាក់បានកើតឡើងនៅក្នុងគ្រួសារ ឬ អាចកើតឡើងនៅពេលអនាគតត្រូវយកចិត្តទុកដាក់ឱ្យបាន ខ្ជាប់ខ្ជួនក្នុងការរក្សាព័ត៌មានដែលទទួលបានទាំងអស់ជាការសម្ងាត់។ ព័ត៌មានដែលទទួលបានពីការប៉ាន់ប្រមាណ ត្រូវកត់ត្រា ក្នុងផែនការករណីរបស់ជនរងគ្រោះ រួមមានផែនការសម្រាប់ទំនាក់ទំនងជាមួយសមាជិកគ្រួសារ ឬ មិត្តភ័ក្រ្ត។

៥- ឯកសារនិងកំណត់ត្រាវេជ្ជសាស្ត្រ និងចិត្តសាស្ត្រផ្សេងៗ រួមទាំងព័ត៌មានអំពីការចាក់ថ្នាំបង្ការ វេជ្ជបញ្ជា និងឱវាទ របស់វេជ្ជបណ្ឌិត ដែលផ្តល់ការព្យាបាល ឬ កោសល្យវិច្ច័យ ។

៦- សំណុំឯកសាររបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំ។

៧- ការបង្ហាញព័ត៌មាន របស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស រួមទាំងព័ត៌មានអំពីស្ថានភាព មេរោគអេដស៍ និងសាវតាគ្រួសាររបស់ជនរងគ្រោះអាចធ្វើទៅបាន លុះត្រាមានការយល់ព្រមពីជនរងគ្រោះ ហើយ ការបង្ហាញនេះ គឺដើម្បីឧត្តមប្រយោជន៍របស់ជនរងគ្រោះជាសំខាន់ ។

៨- ត្រូវរៀបចំតម្កល់សំណុំឯកសារទាំងអស់របស់ជនរងគ្រោះ នៅកន្លែងដែលមានសុវត្ថិភាព និងអាចរក្សា ការសម្ងាត់បាន ។

៩- ជនរងគ្រោះមានសិទ្ធិពេញលេញក្នុងការពិនិត្យមើលសំណុំឯកសាររបស់ខ្លួន រួមទាំងប្រវត្តិឯកសារផ្ទាល់ខ្លួន និងកំណត់ត្រាវេជ្ជសាស្ត្រ ។ ប្រសិនបើជនរងគ្រោះមានការប៉ះទង្គិចផ្លូវចិត្តនៅពេលពិនិត្យមើលសំណុំឯកសារ អ្នកផ្តល់សេវា ត្រូវផ្តល់ការគាំទ្រផ្នែកផ្លូវចិត្ត ដល់ជនរងគ្រោះជាបន្ទាន់ ។ ដើម្បីអនុវត្តការរៀបចំ តម្កល់ឯកសាររបស់ជនរងគ្រោះ ឱ្យបានល្អប្រសើរ អ្នកផ្តល់សេវាកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្សទាំងអស់ ត្រូវយកចិត្តទុកដាក់ អនុវត្តតាមតារាងឧបសម្ព័ន្ធស្តីពីទម្រង់ទាំង ៧ និងទម្រង់ពិសេសចំនួន ២ ដែលមានចែងនៅក្នុងសារាចរណែនាំ លេខ ០០៩ ស.អ.យ ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៧ ស្តីពីការងារសមាហរណកម្ម និងតាមដានក្រុមជនរងគ្រោះ ដែលស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល។

**ប្រការ ១២.–**

ដើម្បីការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស អ្នកផ្តល់សេវាត្រូវសិក្សាស្វែងយល់ពី មាត្រា៤៩ នៃច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងកេងប្រវ័ញ្ចផ្លូវភេទ។ ច្បាប់នេះចែងថា សារព័ត៌មាន និងគ្រប់ មធ្យោបាយផ្សព្វផ្សាយដទៃទៀត ត្រូវហាមឃាត់មិនឱ្យធ្វើការបោះពុម្ពផ្សាយ ឬ ផ្សព្វផ្សាយនូវព័ត៌មានដែលអាចធ្វើ ឱ្យសាធារណជន ដឹងអំពីអត្តសញ្ញាណរបស់ជនរងគ្រោះ ក្នុងបទល្មើសទាំងឡាយដែលមានចែងនៅក្នុងច្បាប់នេះ។

គ្រប់កាលៈទេសៈ ការផ្សាយព័ត៌មានអំពីជនរងគ្រោះ និងការទំនាក់ទំនងជាមួយជនរងគ្រោះ ត្រូវគោរព និងការពារផលប្រយោជន៍របស់ជនរងគ្រោះ ហើយត្រូវបង្ហាញឱ្យឃើញថា ការផ្សាយដោយរំលោភសិទ្ធិជនរងគ្រោះ ជា អំពើល្មើសច្បាប់ ពិសេសមិនត្រូវបង្ហាញមុខជនរងគ្រោះជាសាធារណៈឡើយ លើកលែងតែការបង្ហាញនោះបម្រើឱ្យផល ប្រយោជន៍ផ្ទាល់ខ្លួនរបស់ជនរងគ្រោះ និងមានការយល់ព្រមពីជនរងគ្រោះ ។

៤-បន្ទាប់ពីរយៈពេល ៣ ខែ អ្នកផ្តល់សេវាកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស មិនបានអនុវត្តតាមបទដ្ឋានអប្បបរមានេះ មន្ត្រីដែលចុះធ្វើការត្រួតពិនិត្យ វាយតម្លៃ ត្រូវធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីមានវិធានការណែនាំ អប់រំ ឬ ផ្អាកកម្មវិធីផ្តល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**ប្រការ ១៤.–**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៥.–**

ស្ថាប័នរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងសប្បុរសជន បាននឹងកំពុងមានគោលដៅផ្តល់សេវាកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវអនុវត្តតាមប្រកាសស្តីពីបទដ្ឋានអប្បបរមានេះ។

**ប្រការ ១៦.–**

នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការ នៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធាននាយកដ្ឋានសុខុមាលភាពសង្គម និងប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត និងអង្គភាពពាក់ព័ន្ធនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានភារកិច្ចរៀងៗខ្លួន អនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ TH

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលារាជធានី ខេត្ត
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- គ្រប់អង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ
- ដូចប្រការ ១៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ